សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងវិស័យឧស្សាហកម្ម និងសិប្បកម្មនៅកម្ពុជាបច្ចុប្បន្ន

ស្រាវជ្រាវពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

ស្រាវជ្រាវដោយ៖

**និស្សិតឈ្មោះ កញ្ញា.ម៉េត ស្រីពេជ្រ**

សាស្ត្រាចារ្យណែនាំ

**លោក ហៀង សាង**

**ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ**

**ឆ្នាំសិក្សា ២០១៦**

ជំនាន់ទី២០

ឆ្នាំសរសេរសារណា២០២០

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំ ម៉េត ស្រីពេជ្រ ជានិស្សិតបរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ជំនាន់ទី២០ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ សូមធ្វើការថ្លែងអំណរគុណ និងសម្តែងនូវកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅជូនចំពោះ៖

លោកឪពុក អ្នកម្តាយ ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សាកូនប្រកបដោយព្រហ្មវិហារធម៌ពិសេសដែលបានផ្គត់ផ្គង់ទំនុកបំរុងគ្រប់បែបយ៉ាងទាំងផ្នែកសម្ភារៈ ថវិកា ស្មារតី និងជួយទំនុកបម្រុងកូនឲ្យបានទទួលការអប់រំចាប់តាំងពីថ្នាក់បឋមសិក្សារហូតមកដល់ពេលបច្ចុប្បន្ននេះ។

ថ្នាក់ដឹកនាំ លោក លោកស្រីសាស្ត្រាចារ្យទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានបង្ហាត់បង្រៀនដល់នាងខ្ញុំយ៉ាងយកចិត្តទុកដាក់នូវគ្រប់មុខវិជ្ជាដ៏មានតម្លៃ ទើបធ្វើឲ្យខ្ញុំទទួលបាននូវចំណេះដឹង ដើម្បីទុកជាទុនដ៏មានប្រសិទ្ធិភាពសម្រាប់កែលម្អជីវិតទៅថ្ងៃអនាគត ។

សូមអរគុណដល់ ឯកឧត្តម សារុន បូទ្ធា រដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដែលបានចំណាយពេលវេលាដ៏មានតម្លៃសម្រាប់ធ្វើការផ្តល់បទសម្ភាសន៍ និងបានរៀបរាប់យ៉ាងក្បោះក្បាយអំពីដំណើរការរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដែលសព្វថ្ងៃបានប្តូរឈ្មោះមកជា ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

ជាពិសេស លោកសាស្ត្រាចារ្យ ហៀង សាង ដែលបានចំណាយទាំងកម្លាំងកាយ និងកម្លាំងចិត្ត ផ្តល់ជាកិត្តិយស ណែនាំ ក៏ដូចជាផ្តល់នូវគំនិតក្នុងការកែលម្អក្នុង ការសរសេរសារណានេះប្រកបដោយជោគជ័យ ដោយមិនគិតពីការនឿយហត់។

ជាចុងក្រោយ នាងខ្ញុំសូមបួងសួងដល់បារមីនៃវត្ថុស័ក្តិសិទ្ធិទាំងពួងនៅលើលោកនេះជួយតាមថែរក្សាលោកអ្នកមានគុណ លោកសាស្ត្រាចារ្យ និងឯកឧត្តម ឲ្យជួបតែសេចក្តីសុខ សេចក្តីចម្រើនគ្រប់ពេលវេលា និងប្រកបដោយពុទ្ធិពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

តាមរយៈការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ អស់រយៈពេលបួនឆ្នាំ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច រួចមក នាងខ្ញុំបានទទួលនូវចំណេះដឹងយ៉ាងច្រើនដោយរួមផ្សំជាមួយនឹងការស្រាវជ្រាវពីស្ថានភាពជាក់ស្តែង អំពីវិស័យ ឧស្សាហកម្ម និងសិប្បកម្ម ផងដែរ។

និក្ខេបបទដែលសិក្សា អំពី**"ការគ្រប់គ្រងវិស័យ ឧស្សាហកម្ម និងសិប្បកម្មនៅកម្ពុជាបច្ចុប្បន្ន"** នេះចងក្រងឡើងដែលបានប្រមូលផ្តុំទៅដោយសៀវភៅ លិខិតបទដ្ឋាន និងព្រះរាជក្រឹត្យ ជាច្រើនទម្រាំបង្កើតបានជាសៀវភៅមួយក្បាលនេះឡើង។

នាងខ្ញុំមានសេចក្តីសោមនស្សរីករាយជាអនេក ដែលបានធ្វើ ការតាក់តែងនូវស្នាដៃនេះឡើង ដោយនាងខ្ញុំបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយ កម្លាំងចិត្ត សម្រិតសម្រាំងទៅលើខ្លឹមសារនៃប្រធានបទ ដើម្បីឲ្យខ្លឹមសារនៃប្រធានបទរបស់នាងខ្ញុំមានភាពច្បាស់លាស់ ក្បោះក្បាយគ្រប់ជ្រុងជ្រោយដើម្បីជាគុណប្រយោជន៍ពិតប្រាកដ។ នាងខ្ញុំ សង្ឃឹម និងជឿជាក់ថាស្នាដៃមួយនេះពិតជាផ្តល់អត្ថប្រយោជន៍ និង ជាទុនក្នុងពង្រីកពុទ្ធិគំនិត និង ចំណេះដឹកក្នុងការស្រាវជ្រាវពីគ្រប់បណ្តាមជ្ឈដ្ឋានអ្នកអានទាំងអស់។

ជាចុងបញ្ចប់ ខ្ញុំសង្ឃឹមថាសារណានេះ នឹងអាចជួយកែលម្អចំណែកក្នុងការសិក្សាស្រាវជ្រាវសម្រាប់និស្សិតជំនាន់ក្រោយ។ ទោះជាយ៉ាងណាសារណានេះ ប្រាកដជាមានកំហុសឆ្គង ដែលមិនអាចជៀសវាងបានដែលត្រូវការជាចាំបាច់នូវការរិះគន់ ក្នុងន័យស្ថាបនា ពីសំណាក់លោកសាស្ត្រចារ្យ រៀមច្បង និងអ្នកសិក្សាស្រាវជ្រាវទាំងអស់ ដើម្បីឲ្យស្នាដៃនេះ ឲ្យកាន់តែមានសុក្រឹត្យភាព ។

យើងខ្ញុំ រង់ចាំទទួលជានិច្ច នូវរាល់ការរិះគន់ទាំងឡាយដោយក្តីរីករាយ ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........ ១

## ជំពូកទី១

## ស្ថានភាពទូទៅ

**១.១ ប្រវត្ត** ........ ៤

**១.២ ទីតាំង** ........ ៦

**១.៣ គោលនយោបាយ** ........ ៧

## ជំពូកទី២

## រចនាសម្ព័ន្ធ

**២.១ រចនាសម្ព័ន្ធគ្រប់គ្រងថ្នាក់ជាតិ** ........ ១០

២.១.១ អគ្គនាយកដ្ឋានកិច្ចការទូទៅ ........ ១០

២.១.២ អគ្គនាយកដ្ឋានឧស្សាហកម្ម ........ ១០

២.១.៣ អគ្គនាយកដ្ឋានសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម ........ ១១

២.១.៤ វិទ្យាស្ថានស្តង់ដារ ........ ១១

២.១.៥ មជ្ឈមណ្ឌលមាត្រាសាស្ត្រ ........ ១១

២.១.៦ អគ្គាធិការដ្ឋាន ........ ១២

២.១.៧ នាយកដ្ឋានសវនកម្មផ្ទៃក្នុង ........ ១២

២.១.៨ អង្គភាពផលិតកម្ម ........ ១២

**២.២ រចនាសម្ព័ន្ធគ្រប់គ្រងថ្នាក់ជាតិ** ........ ១២

## ជំពូកទី៣

## របកគំហើញក្នុងការគ្រប់គ្រង

**៣.១ លទ្ធផលការងារតាមវិស័យជំនាញ** ........ ១៤

៣.១.១ វិស័យឧស្សាហកម្ម ........ ១៤

៣.១.១.១ កិច្ចការឧស្សាហកម្ម ........ ១៤

ក. ការចុះបញ្ជីរោងចក្រ ........ ១៤

ខ. តម្លៃសរុបបរិមាណផលិតផល ........ ១៥

៣.១.១.២ ការងារកម្មសិទ្ធឧស្សាហកម្ម................................................................................................................១៥
ក. ការងារបញ្ញាតិកម្ម ....................................................................................................................................១៥
ខ. ការចុះបញ្ជី....................................................................................................................................................១៥
៣.១.២ វិស័យសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម ................................................................................១៦
៣.១.២.១ សហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម.........................................................................................១៦
៣.១.២.២ ការងារជំរុញ និងអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម............................................១៦
៣.១.៣ វិស័យទឹកស្អាត.............................................................................................................................................១៧
៣.១.៤ ការងារស្តង់ដារនីយកម្ម................................................................................................................................១៨
៣.១.៤.១ ការងារអភិវឌ្ឍស្តង់ដារ..............................................................................................................................១៨
៣.១.៤.២ ការងារវិញ្ញាបនបត្រកម្ម..........................................................................................................................១៨
៣.១.៥ ការងារមាត្រាសាស្ត្រ.....................................................................................................................................១៩
៣.១.៦ ផ្នែកកិច្ចការទូទៅ ..........................................................................................................................................១៩
៣.១.៦.១ ការងារនីតិកម្ម.............................................................................................................................................១៩
៣.១.៦.២ ការងារផែនការ ស្ថិតិ សហប្រតិបត្តការ និងការងារអាស៊ាន ................................................................២០
៣.១.៧ ការងាររបស់មន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្ត ...................................................................២០
៣.១.៧.១ ការងារឧស្សាហកម្ម និងសិប្បកម្ម.........................................................................................................២០
៣.១.៧.២ ការងារស្តង់ដារ និងមាត្រាសាស្ត្រ..........................................................................................................២១
៣.១.៨ ការងារអគ្គាធិការដ្ឋាន និងសវនកម្មផ្ទៃក្នុង ...........................................................................................២១

**ជំពូកទី៤**

**បញ្ហាប្រឈម**

**៤.១ បញ្ហាធនធានមនុស្ស** ..........................................................................................................២៣
**៤.២ បញ្ហាធនធាន** ........................................................................................................................២៤
**៤.៣ បញ្ហាច្បាប់** ...........................................................................................................................២៥
**សេចក្តីសន្និដ្ឋាន**...........................................................................................................................២៧
**អនុសាសន៍**.................................................................................................................................២៨
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ចាប់តាំងពីឆ្នាំ១៩៩៨ មកប្រទេសកម្ពុជាទទួលបានសុខសន្តិភាព ពេញលេញក្រោមការដឹកនាំដ៏ជោគជ័យនៃគោលនយោបាយឈ្នះៗ របស់រាជរដ្ឋាភិបាល។ ក្នុងនោះ គ្រប់វិស័យទាំងអស់ត្រូវបានរីកដុះដាលជាបន្តបន្ទាប់ ជាពិសេសវិស័យឧស្សាហកម្ម និងសិប្បកម្ម គឺជាវិស័យដ៏សំខាន់មួយដែលជួយជំរុញដល់ការ អភិវឌ្ឍរបស់ប្រទេស និងជាកត្តាលីករមួយជួយសេដ្ឋកិច្ចកម្ពុជាឲ្យទទួលបានភាពរីកចម្រើនកាន់តែច្រើនឡើងៗពីមួយឆ្នាំទៅមួយឆ្នាំ។

តាមរយៈកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ក្នុងរង្វង់ជាមធ្យមប្រមាណ៧% ក្នុងមួយឆ្នាំសម្រាប់ពីរទស្សវត្សចុងក្រោយនេះ ដែលគាំទ្រដោយកំណើននៃវិស័យឧស្សាហកម្ម កម្មន្តសាល សំណង់ កសិកម្ម សេវាកម្ម ទេសចរណ៍ អចលនទ្រព្យ គមនាគមន៍ និងដឹកជញ្ជូន ធ្វើឲ្យប្រទេសកម្ពុជាចាកចេញពីឋានៈជាប្រទេសមានប្រាក់ចំណូលទាប មកជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាបនៅឆ្នាំ២០១៥ និងឈានទៅសំរេចបានជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ សម្រាប់ឆ្នាំ២០១៨ សេដ្ឋកិច្ចកម្ពុជាមានកំណើនលើសពីការរំពឹងទុក[1]។

ក្នុងនោះ វិស័យឧស្សាហកម្មបានចូលរួមចំណែកក្នុងផលទុនសរុបក្នុងស្រុកក្នុងរង្វង់៣២.៤%។ ឈរលើមូលដ្ឋាននេះ ចំណូលមធ្យមប្រចាំរបស់ប្រជាពលរដ្ឋម្នាក់ៗកើនដល់១,៥៦៣ដុល្លារអាមេរិក ហើយ អត្រានៃភាពក្រីក្របានថយចុះមកនៅក្នុងរង្វង់១០%នាពេលបច្ចុប្បន្ន។ ជាក់ស្តែង សម្រាប់ឆ្នាំ២០១៩នេះ សេដ្ឋកិច្ចកម្ពុជាមានកំណើនក្នុងអត្រា៧.១% ប្រហាក់ប្រហែលនិងកំណើនឆ្នាំ២០១៨ អាស្រ័យដោយមានការគាំទ្រកំណើនរឹងមាំនៃវិស័យឧស្សាហកម្ម និងកំណើននៃសេដ្ឋកិច្ចសេវាកម្ម។ ផលទុនសរុបក្នុងស្រុកសម្រាប់ឆ្នាំ២០១៩នេះបានកើនឡើងដល់១,៧០៦ ដុល្លារអាមេរិក[2]។

ក្នុងនោះ ក្រសួងឧស្សាហកម្ម និងសិប្បកម្មបានដំណើរការរូបិយកម្មនូវគោលនយោបាយនិងយុទ្ធសាស្ត្រនានារបស់រាជរដ្ឋាភិបាលឲ្យក្លាយជាផែនការសកម្មភាពជាក់ស្តែងតាមបណ្តាឆ្នាំថវិកាជាតិ។

## ២. ចំណោទបញ្ហានៃការដោះស្រាយ

ទោះបីជាកំណើនសេដ្ឋកិច្ចជាតិមានការរីកចម្រើនយ៉ាងណាក៏ វិស័យឧស្សាហកម្ម និង សិប្បកម្មនៅតែមានកង្វះខាត និងបញ្ហាមួយចំនួនកើតឡើងដូចជា ការគ្រប់គ្រងរោងចក្រ និងសិប្បកម្មនៅមានកម្រិត ដោយក្នុងនោះមានសិប្បកម្ម និងរោងចក្រមួយចំនួនលួចបើកខុសច្បាប់ និងមិនព្រមចុះបញ្ជីកាលត្រឹមត្រូវតាមក្រសួងបានកំណត់ និងមានបញ្ហាស្តង់ដារជាដើម។

[1] របាយការណ៍ បូកសរុបលទ្ធផលការងាររបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប្រចាំឆ្នាំ២០១៩ និងទិសដៅការងារឆ្នាំ២០២០

[2] របាយការណ៍ បូកសរុបលទ្ធផលការងាររបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប្រចាំឆ្នាំ២០១៩ និងទិសដៅការងារឆ្នាំ២០២០

ហេតុដូចនេះហើយ បានជាមានសំណួរតែងតែចោទសួរថា៖
តើវិស័យឧស្សាហកម្ម និងសិប្បកម្មបានផ្តល់នូវប្រយោជន៍អ្វីខ្លះ ដល់ប្រទេសជាតិ? ក្នុងមួយឆ្នាំៗ។
តើក្រសួងឧស្សាហកម្ម និងសិប្បកម្មទទួលបានលទ្ធផលអ្វីខ្លះតាមវិស័យដែលក្រសួងនេះគ្រប់គ្រង?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលគំនិតសំខាន់នៃការស្រាវជ្រាវ នេះគឺចង់ផ្តល់ឲ្យមិត្តអ្នកអានទទួលបាននូវចំណេះដឹងអំពីវិស័យឧស្សាហកម្ម និងសិប្បកម្មនៅកម្ពុជា ថាតើវិស័យនេះគ្រប់ដណ្តប់លើផ្នែកអ្វីខ្លះ និងទទួលបានទិន្នផលអ្វីខ្លះពីផ្នែកទាំងនោះ និងដឹងពីគោលនយោបាយដែលក្រសួងកំពុងតែអភិវឌ្ឍ និងនៅពេលអនាគតក្នុងឆ្នាំ២០២៥។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ដោយសារប្រធានបទនេះ មានភាពទូលំទូលាយ និងជាពិសេសដើម្បីសម្រួលដល់ការសិក្សាស្រាវជ្រាវ នាងខ្ញុំសូមអនុញ្ញាតទាញចំណាប់អារម្មណ៍អ្នកឈ្វេងយល់ប្រធានបទមួយនេះ តែទៅលើ ប្រវត្តិ រចនាសម្ព័ន្ធ លទ្ធផលតាម វិស័យជំនាញ និងបញ្ហាប្រឈម ហើយបន្ថែមនូវ គោលនយោបាយតម្រង់ទិស ២០១៥ - ២០២៥។ ដោយទិន្នន័យដែលមាននៅក្នុងសៀវភៅនេះគឺជា ទិន្នន័យចុងក្រោយក្នុងឆ្នាំ២០១៩។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានសារៈសំខាន់ដល់ អ្នកអាន អ្នកស្រាវជ្រាវ និងខ្លួនឯងផ្ទាល់តែម្តង។ សារៈសំខាន់ចំពោះ អ្នកស្រាវជ្រាវជាឯកសារគឺជួយបំភ្លឺក៏ដូចជាគំរូបន្ថែមដល់អ្នកស្រាវជ្រាវជំនាន់ក្រោយ យកទៅស្រាវជ្រាវបន្ត។

សរុបមកសារណានេះ និងជួយជាដើមទុនដែលធ្វើអោយកាន់តែយល់បានស៊ីជម្រៅទាក់ទងទៅ និងការគ្រប់គ្រប់វិស័យឧស្សាហកម្ម និងសិប្បកម្ម។ ជាការពិតទៅសារណាបញ្ចប់ការសិក្សាមួយនេះ និងអាចរួមចំណែកក្នុងការអនុវត្ត និងស្មារតីបន្ថែមទៅដល់ប្រជាពលរដ្ឋខ្មែរ ជាពិសេសគឺមិត្តអ្នកអានទាំងអស់គ្នា។

## ៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ពឹងផ្អែកទៅលើសៀវភៅសន្និបាតប្រចាំឆ្នាំជាចម្បងបូកផ្សំនិងព្រះរាជក្រមមួយចំនួន។ ក្រៅពីសៀវភៅ និងព្រះរាជក្រម ក៏នៅមានអនុសាសន៍ខ្លះៗរបស់ ឯកឧត្តមរដ្ឋលេខាធិការ នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដែលឯកឧត្តមបានចំណាយពេលវេលាដ៏មានតម្លៃ ផ្តល់នូវគោលគំនិត និងការរៀបរាប់អំពីដំណើរការ និងដែនគ្រប់គ្រងរបស់ក្រសួង។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីឲ្យកាន់តែច្បាស់ និងងាយស្រួលក្នុងការបកស្រាយប្រធានបទ “ការគ្រប់គ្រង់វិស័យឧស្សាហកម្ម និងសិប្បកម្មនៅកម្ពុជាបច្ចុប្បន្ន” ជាដំបូងយើងនឹងធ្វើការបកស្រាយអំពី ប្រវត្ត ទីតាំង និងគោលនយោបាយ របស់ក្រសួងក្នុងជំពូកទី១។ ចំណែកឯ ជំពូលទី២វិញ នឹងនិយាយអំពី រចនាសម្ព័ន្ធថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ រីឯ ជំពូកទី៣

នឹងបង្ហាញអំពី របកគំហើញតាមវិស័យជំនាញរបស់ក្រសួង និងជំពូកបន្ទាប់ ជំពូកទី៤ នឹងនិយាយអំពី បញ្ហាប្រឈម ដែលកំពុងតែជួបប្រទេះបច្ចុប្បន្ន។

# ជំពូកទី១
# ស្ថានភាពទូទៅ

## ១.១ ប្រវត្តិ

ព្រះរាជាណាចក្រកម្ពុជាទទួលបានឯករាជ្យពីសាធារណរដ្ឋបារាំងនៅថ្ងៃទី០៩ ខែវិច្ឆកា ឆ្នាំ១៩៥៣ ហើយតាំងពីពេលនោះមកវិស័យឧស្សាហកម្ម និងសិប្បកម្មគឺជាវិស័យដ៏សំខាន់មួយរបស់កម្ពុជា ក្នុងរបបនយោបាយជាបន្តបន្ទាប់ដោយប្រទេសយើងចាប់ផ្តើមមានរោចក្រ ខ្សែសង្វាក់ផលិតកម្ម តម្បាញ និងសប្បកម្ម ដ៏សំបូរបែបជាបន្តបន្ទាប់ ជាពិសេសក្នុងរបបសង្គមរាស្ត្រនិយម ដូចដែលយើងទាំងអស់គ្នាបានឃើញតាម រយៈភាពយន្តឯកសារជាច្រើន ដែលបានឆ្លុះបញ្ចាំងពីភាពរីកចម្រើននាសម័យនោះ។ ក៏ប៉ុន្តែ ក្នុងទំព័រប្រវត្តិសាស្ត្រដ៏ខ្មៅងងឹត ៣ឆ្នាំ ៨ខែ ២០ថ្ងៃនៃរបបកម្ពុជាប្រជាធិបតេយ្យ ប្រល័យពូជសាសន៍ ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ វិស័យឧស្សាហកម្ម ក៏ដូចជាវិស័យផ្សេងៗទៀត ត្រូវបានបោះបង់ចោល ក្រោមគោលនយោបាយដ៏ឆ្កួតលីលា ដែលតម្រូវឲ្យប្រជាជនទូទាំងប្រទេស ជម្លៀសទៅធ្វើស្រែនៅជនបទទាំងអស់ ទោះបីជានិក្ខេបបទបណ្ឌិតផ្នែកសេដ្ឋកិច្ចរបស់ខៀវ សំផន ដែលកាលនោះមានតួនាទីជាប្រមុខរដ្ឋ និយាយអំពី ទំនើបភាវូបនីយកម្មឧស្សាហកម្មនៅកម្ពុជាក៏ដោយ។ ទើបតែក្រោយថ្ងៃរំដោះ០៧ មករា ឆ្នាំ១៩៧៩ វិស័យឧស្សាហកម្មនិងសិប្បកម្មត្រូវបានចាប់ផ្តើមកសាង រៀបចំឡើងវិញជា បន្តបន្ទាប់ តែដោយ រោចក្រ និងសិប្បកម្មនៅក្នុងប្រទេស ស្ថិតនៅជាសហគ្រាសរដ្ឋ ដោយក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា មិនទាន់បើកចំហរទីផ្សារនៅឡើយ។ ក្នុងបរិបទសង្គ្រាមត្រជាក់រវាងលោកខាងលិចដែលប្រកាន់យករបប មូលធន ទីផ្សារសេរី និងរបបសង្គមនិយម ដែលប្រកាន់យករបបសេដ្ឋកិច្ចផែនការ ដូចកម្ពុជានាសម័យនោះប្រទេសអាស៊ីអាគ្នេយ៍មួយនេះ ត្រូវបានហ៊ុមព័ទ្ធសេដ្ឋកិច្ចពីរយៈលោកខាងលិច ដោយគេចោទប្រកាន់ថាវៀតណាមបានចូលឈ្លានពានកម្ពុជា ហើយបានប្រគល់អាសន្នៈអង្គការសហប្រជាជាតិកម្ពុជាឲ្យទៅរដ្ឋាភិបាលនិរទ្ទេសត្រីភាគី ដែលក្នុងនោះមានកម្លាំងខ្មែរក្រហមដែលជាកម្លាំងស្នូល។ សង្គ្រាមត្រជាក់ដែលប៉ូលម្ខាង ដឹកនាំដោយសហរដ្ឋអាមេរិក និងប៉ូលម្ខាងទៀតដឹកនាំដោយអតីតសហភាពសូវៀតបានឈានដល់ការរត់ប្រណាំងសព្វាវុធ ដែលធ្វើឲ្យសេដ្ឋកិច្ចអតីតសហភាព សូវៀតធ្លាក់ចុះ ឈានដល់ការកាត់ជំនួយដល់ប្រទេសជាមិត្ត ក្នុងនោះក៏មានកម្ពុជាផងដែរ ក្នុងខណៈដែលកម្ពុជា ដែលរងគ្រោះដោយការហ៊ុមព័ន្ធសេដ្ឋកិច្ចមិនមានទំនាក់ទំនងសេដ្ឋកិច្ច ឬជំនួយអ្វីក្រៅពីប្រទេសសង្គមនិយមមួយចំនួនដែលក្នុងនោះអតីតសហភាពសូវៀតជាម្ចាស់ជំនួយធំជាងគេនាសម័យនោះ។ ក្នុងបរិបទនេះហើយដែលថ្នាក់ដឹកនាំសាធារណរដ្ឋប្រជាមានិតកម្ពុជាចាប់តាំងពីពាក់កណ្តាល់ទសវត្សរ៍៨០ មកបានកត់សំគាល់ពីការធ្លាក់ចុះនៃការបញ្ជាទិញកៅស៊ូ ដែលតំណាងឲ្យវិស័យឧស្សាហកម្មដ៏សំខាន់មួយនៃកម្ពុជានាពេលនោះពីសំណាក់អតីតសហភាពសូវៀត ហើយពិសេសជាងនេះទៅទៀតនោះគឺប្រទេសមួយចំនួននៅក្នុងសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ ហៅកាត់ថាអាស៊ាន ដូចជាម៉ាឡេស៊ីជាដើម ផ្តល់តម្លៃខ្ពស់ជាងចំពោះការទិញកៅស៊ូពីកម្ពុជា។

ប្រហែលមកពីហេតុផលអស់ទាំងនេះហើយ ដែលភាគច្រើនគ្មានអ្នកណាដឹង ផ្គូប់ផ្គុំនិងកត្តាក្នុងស្រុកនិងពិភពលោក បានជំរុញឲ្យមានការចរចារស្វែងរកសន្តិភាពនៅកម្ពុជាដែលចាប់ផ្តើមពីការជួបមុខគ្នាផ្ទាល់ជាលើកដំបូងរវាងសម្តេច នរោត្តម សីហនុ និងសម្តេច ហ៊ុន សែន នៅ សាធារណរដ្ឋបារាំងថ្ងៃទី០២ ខែធ្នូ ឆ្នាំ១៩៨៧ រហូតដល់ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងទីក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ និងការបង្កើតរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញតាមរយៈការអនុម័តរដ្ឋធម្មនុញ្ញដែលព្រះរាជាណាចក្រកំពុងប្រើប្រាស់ដល់ បច្ចុប្បន្ននៅ ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ ដោយសភាធម្មនុញ្ញ។ ក្រោយការបោះឆ្នោតជាសកលលើកទី១រៀបចំដោយអង្គការសហប្រជាជាតិចន្លោះពីថ្ងៃទី២៣ ដល់ថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៣ រាជរដ្ឋាចំរុះមួយត្រូវបានបង្កើតឡើង ហើយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក៏ត្រូវបានចាប់បដិសន្ធិឡើងជាផ្លូវការតាំងពីពេលនោះមក។ រហូតដល់ក្រោយការបោះឆ្នោតថ្ងៃទី២៨ ខែកក្កដា ឆ្នាំ ២០១៣ ទើបរាជរដ្ឋាភិបាលបានស្នើសុំទៅសភាឲ្យបំបែកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ទៅជាពីរគឺក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដែលត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣[3]។

ក្រសួងរ៉ែ និងថាមពល ដែលត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែ និងថាមពល នៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១២ ខែវិច្ឆកា ឆ្នាំ២០១៣ នាសម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២១ ខែវិច្ឆកា ឆ្នាំ២០១៣ នាសម័យប្រជុំវិសាមញ្ញនីតិកាលទី៣ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញបញ្ជាក់ពីធម្មនុញ្ញភាពក្នុងសេចក្តីសំរេចលេខ១៤៦/០២១/២០១៣ កបធ.ច ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៣[4]។ រហូតដល់ ថ្ងៃទី២៦ ខែមីនា ឆ្នាំ ២០២០ ព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ បានប្រកាសឲ្យប្រើច្បាប់ស្តីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវនុវត្តន៍ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២០ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៤ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ ២០១/០០១/២០២០ កបធ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ ២០២០[5]។

[3] ព្រះរាជក្រមលេខ នស/ រកម/ ១២១៣/ ០១៨, ០៦ ធ្នូ ២០១៣, មាត្រា១។

[4] ព្រះរាជក្រមលេខ នស/ រកម/ ១២១៣/ ០១៧, ០៦ ធ្នូ ២០១៣, មាត្រា១។

[5] ព្រះរាជក្រមលេខ នស/ រកម/ ០៣២០/ ០០៩, ២៦ មីនា ២០២០, មាត្រា១។

## ១.២ ទីតាំង

បន្ទាប់ពីរបបកម្ពុជាប្រជាធិតេយ្យបានផុតរលត់ទៅ និងក្រោយកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសឆ្នាំ១៩៩១ និងការបោះឆ្នោតជាសកលនៅឆ្នាំ១៩៩៣ ព្រះរាជាណាចក្រកម្ពុជាទី២ក៏បានលេចឡើងជាថ្មីម្តងទៀត។ នៅឆ្នាំ១៩៩៣គ្រប់ក្រសួងស្ថាប័នទាំងអស់ត្រូវបានបង្កើតឡើងជាបន្តបន្ទាប់។ ក្នុងនោះក៏មានក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលផងដែរ ដែលមានទីតាំងស្ថិតនៅដីឡូតិ៍លេខ៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មីទី៣ ខណ្ឌដូនពេញ ដែលជាទីតាំងប្រើប្រាស់សម្រាប់ជាទីស្តីការក្រសួង។ ការបោះឆ្នោតជាសកលក៏ត្រូវបានបង្កើតឡើង នៅពេលនោះក៏ជាប្រវត្តិសាស្រ្តរបស់ប្រទេសកម្ពុជាផងដែរ ដែលមាន នាយករដ្ឋមន្ត្រីដល់ទៅពីររូបគឺ សម្តេចនរោត្តម រណឬទ្ធិ ដែលមកពីគណបក្សហ្វ៊ុនស៊ិនប៉ិច ជានាយករដ្ឋមន្ត្រីទី១ និងសម្តេច ហ៊ុន សែន ដែលមកពីគណបក្សប្រជាជនកម្ពុជា ជានាយករដ្ឋមន្ត្រីទី២[6]។ ចាប់តាំងពីឆ្នាំ១៩៩៤ គណបក្សទាំងពីរចាប់ផ្តើមមានភាពវង្វេងវង្វើរនិងគ្នា រហូតនៅថ្ងៃទី៥ដល់ថ្ងៃទី៦ ខែកក្កដា ឆ្នាំ១៩៩៧ មានព្រឹត្តិការណ៍ផ្ទុះអាវុធប្រយុទ្ធគ្នារវាងគណបក្សទាំងពីរ ហើយជាលទ្ធផល ឯកឧត្តម អ៊ឹង ហ៊ួត ដែលមកពីគណបក្សហ្វ៊ុនស៊ិនប៉ិចជាអ្នកឡើងកាន់តំណែងជានាយករដ្ឋមន្ត្រីទី១ ដើម្បីបន្តការងារក្នុងរាជរដ្ឋាភិបាលនិងសម្តេច ហ៊ុន សែនដែលមកពីគណបក្សប្រជាជនកម្ពុជាជានាយករដ្ឋមន្ត្រីទី២ដដែល[7]។ នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៨ ការបោះឆ្នោតថ្នាក់ជាតិលើកទី២ក៏បានដំណើរការតាមការព្រៀងទុក ដោយនៅពេលនោះ គណៈបក្សប្រជាជនកម្ពុជា ទទួលបាន៦៤ អាសនៈក្នុងរដ្ឋសភា និង គណបក្សហ្វ៊ុនស៊ិនប៉ិចទទួលបាន៤៣អាសនៈ។ តាមរដ្ឋធម្មនុញ្ញ រាជរដ្ឋាភិបាលត្រូវជ្រើសតាំងដោយសំលេងគាំទ្រ ពីរភាគបីនៃចំនួនតំណាងរាស្រ្ត[8]។ ដោយក្នុងនោះ សម្តេច នរោត្តម រណឬទ្ធិ ត្រូវបានតែងតាំងជាប្រធានរដ្ឋសភា សម្តេច ជា ស៊ីម ជាប្រធានព្រឹទ្ធសភា និងសម្តេច ហ៊ុន សែន ជានាយករដ្ឋមន្ត្រី។ នៅក្នុងឆ្នាំ១៩៩៨នេះហើយជាឆ្នាំដែលប្រទេសកម្ពុជាទទួលបានសុខសន្តិភាពពេញលេញបន្ទាប់ពីការអនុវត្តនូវគោលនយោបាយឈ្នះៗរបស់សម្តេចអគ្គមហាសេនាតេជោ ហ៊ុន សែន។ នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ រាជរដ្ឋាភិបាលបានស្នើសុំទៅសភាឲ្យបំបែកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ទៅជាពីរគឺ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងរ៉ែ និងថាមពល។ ដោយក្រសួងរ៉ែ និងថាមពល ស្ថិតនៅតាម បណ្តោយផ្លូវលេខ៤៦(ផ្លូវប៉ាស្ទ័រ) សង្កាត់ផ្សារថ្មីទី៣ ខណ្ឌដូនពេញ និងស្ថិតនៅតាមបណ្តោយផ្លូវសហព័ន្ធរុស្ស៊ី(អតតីអាជ្ញាធរប្រេងកាតកម្ពុជាប្រែមកជាអគ្គនាយកដ្ឋានប្រេងកាត ចំណុះឲ្យក្រសួងរ៉ែ និងថាមពល)ដឹកនាំដោយ ឯកឧត្តម ស៊ុយ សែម[9]។ ចំណែកឯ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ទោះបីប្តូរទៅជាក្រសួងឧស្សាហកម្ម វិទ្យាសាស្រ្ត

[6] សារឌី, ២០១៨

[7] សារឌី, ២០១៨

[8] រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

[9] www.mme.gov.kh

បច្ចេកវិទ្យា និងនវានុវត្តន៍ ក៏ទីតាំងរបស់ក្រសួងនេះស្ថិតនៅទីតាំងដដែល ដោយដឹកនាំដោយឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិតទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធិ។

ប៉ុន្តែក៏នៅមានវិទ្យាស្ថាន និងមជ្ឈមណ្ឌលមួយចំនួនស្ថិតនៅទីតាំងផ្សេងៗគ្នាផងដែរ ដូចជាមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ(ម.ម.ជ.) ស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៥ និងវិទ្យាស្ថានស្តង់ដារកម្ពុជា ដែលមានទីតាំងស្ថិតនៅតាម បណ្តោយផ្លូវជាតិលេខ២ (ប្រធានមជ្ឈមណ្ឌល និងវិទ្យាស្ថាន មានឋានៈស្មើអគ្គនាយក) ហើយក៏នៅមានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៅគ្រប់២៥ រាជធានី ខេត្ត។

## ១.៣ គោលនយោបាយ

វិស័យឧស្សាហកម្មនៅកម្ពុជា ដែលគ្របទាំងវិស័យសិប្បកម្ម ហើយបច្ចុប្បន្នត្រូវបានពង្រីកវិសាលភាពគ្រប់ដណ្តប់វិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ថែមទៀតនោះ ត្រូវបាននិងកំពុង **អភិវឌ្ឍន៍តាមគោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥ ២០២៥ "តម្រង់ទិសទីផ្សារ និងបង្កើតលក្ខខណ្ឌអំណោយផល ដើម្បីជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្ម"** ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៥ ដែលជាត្រីវិស័យសម្រាប់បន្តអភិវឌ្ឍន៍វិស័យឧស្សាហកម្មនៅកម្ពុជារហូតដល់ឆ្នាំ២០២៥។

ឯកសារនេះបានបង្ហាញពីភាពចាំបាច់នៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ដោយចាត់ទុកវិស័យឧស្សាហកម្មជាមូលដ្ឋានគ្រឹះនៃកំណើនសេដ្ឋកិច្ចកម្ពុជា ហើយក៏បានបង្ហាញពីស្ថានភាពឧស្សាហកម្មនៅកម្ពុជាដែលក្នុងនោះមានទាំង ទិដ្ឋភាពរួមនៃរចនាសម្ព័ន្ធឧស្សាហកម្ម និងបញ្ហាប្រឈមគន្លឹះៗនៃការអភិវឌ្ឍ វិស័យឧស្សាហកម្មនៅកម្ពុជា។ ក្នុងទិដ្ឋភាពរួមនៃរចនាសម្ព័ន្ធឧស្សាហកម្ម ឃើញថាសកម្មភាពឧស្សាហកម្ម នៅកម្ពុជានៅមានសភាពទន់ខ្សោយ ដែលឆ្លុះបញ្ចាំងពីរចនាសម្ព័ន្ធផលិតកម្មសាមញ្ញ និងតូចចង្អៀត ព្រមទាំងប្រមូលផ្តុំជុំវិញផលិតកម្មសម្លៀកបំពាក់ និងការកែច្នៃអាហារ ហើយមូលដ្ឋានផលិតភាគច្រើនមានលក្ខណៈជាគ្រួសារ ដែលសហគ្រិនភាព និងការប្រើប្រាស់បច្ចេកវិទ្យាមានកម្រិតទាប ដោយមិនទាន់មាន សមត្ថភាពប្រកួតប្រជែងក្នុងទីផ្សារអន្តរជាតិ។ ជាមួយគ្នានេះ ឧស្សាហកម្មនៅកម្ពុជាមានលក្ខណៈសម្បត្តិ សំខាន់ៗមួយចំនួនដូចជា មូលដ្ឋានឧស្សាហកម្មមិនសូវសម្បូរបែបរចនាសម្ព័ន្ធឧស្សាហកម្មប្រហោងកណ្តាលនិងក្រៅផ្លូវការ សហគ្រិនភាពនៅទន់ខ្សោយនិងប្រមូលផ្តុំតែនៅទីក្រុង និងតម្លៃបន្ថែមទៀត និងបច្ចេកវិទ្យាទន់ខ្សោយ។

រីឯបញ្ហាប្រឈម គន្លឹះៗនៅកម្ពុជាមាន (១)ភាពជាអ្នកដឹកនាំ ការសម្របសម្រួល និងការសម្រេចចិត្តប្រកបដោយប្រសិទ្ធិភាព (២) មូលដ្ឋានចំណេះដឹកផ្នែកបច្ចេកទេស និងជំនាញ (៣)ការតភ្ជាប់ជាពីរ ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ និងការសម្របសម្រួល (ទោះបីមានការខិតខំប្រឹងប្រែងជាខ្លាំងក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធកន្លងមក ហេដ្ឋារចនាសម្ព័ន្ធទាំងនោះមិនទាន់គ្រប់គ្រាន់ បញ្ហាប្រឈមដ៏សំខាន់ក្នុងការអភិវឌ្ឍឧស្សាហកម្មគឺ កង្វះការផ្គត់ផ្គង់អគ្គិសនីមួយមានស្ថេរភាព និងមានតម្លៃប្រកួតប្រជែងហេដ្ឋារចនាសម្ព័ន្ធចាំបាច់ដូចជា ទឹកស្អាត ប្រព័ន្ធបង្ហូរទឹកកង្វក់ត្រូវគិតគូរឡើងវិញក្នុងទំហំថ្មី (៤)ស្ថានភាពទីផ្សារហិរញ្ញវត្ថុ ការអភិវឌ្ឍវិស័យធនាគារ រួមទាំងមីក្រូហិរញ្ញវត្ថុមានសន្ទុះខ្លាំង ក្នុង

រយៈពេល មួយទសវត្សរ៍ចុងក្រោយក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ប៉ុន្តែមិនទាន់ឆ្លើយតបបានទៅនិងតម្រូវការឆ្លើយតបនៅឡើយ (៥)បញ្ហាទីផ្សារការងារនិងទំនាក់ទំនងវិជ្ជាជីវៈ (ទំនាក់ទំនងវិជ្ជាជីវនៅតែជាបញ្ហាចម្បងសម្រាប់ការអភិវឌ្ឍ វិស័យឧស្សាសហកម្មនៅកម្ពុជា ហើយបញ្ហានេះកើតឡើយនៅគ្រប់ប្រទេស ក្នុងដំណាក់កាលនៃការផ្លាស់ប្តូរជីវភាពពីកសិកម្មជនបទមកឧស្សាហកម្មទីក្រុង)[10]។

ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលគឺជំរុញកែប្រែ និងធ្វើទំនើបកម្មរចនាសម្ព័ន្ធឧស្សាកម្មនៅកម្ពុជា ពីឧស្សាហកម្មអតិពលកម្មឈានទៅឧស្សាហកម្មផ្អែកលើជំនាញនៅឆ្នាំ២០២៥ តាមរយៈការតភ្ជាប់ទៅនិងខ្សែសង្វាក់តម្លៃសកលសមាហរណកម្មទៅក្នុងបណ្តាយផលិតកម្មតំបន់ និងការអនុវត្តកន្សោមឧស្សាហកម្មប្រទាក់ក្រឡាទន្ទឹមនិងការពង្រឹងភាពប្រកួតប្រជែង និងការលើកកម្ពស់ផលិតភាពក្នុងស្រុកហើយឈានទៅរកការអភិវឌ្ឍឧស្សាហកម្មទំនើប ដោយផ្អែកជាសំខាន់ទៅលើមូលដ្ឋានបច្ចេកវិទ្យា និងចំណេះដឹង។

តាមចក្ខុវិស័យខាងលើរាជរដ្ឋាភិបាល និងយកចិត្តទុកដាក់ជំរុញការផ្លាស់ប្តូររចនាសម្ព័ន្ធក្នុងដំណាក់កាល៣សំខាន់គឺការបន្តជំរុញសក្តានុពល និងពិពិធកម្មឧស្សាហកម្ម អតិពលកម្ម រួមមានឧស្សាហកម្ម កម្មន្តសាល និងកសិ-ឧស្សាហកម្មក្នុងដំណាក់កាលដំបូង ការជំរុញការផ្លាស់ប្តូរស៊ីជម្រៅនៃរចនាសម្ព័ន្ធ ឧស្សាហកម្មទូទៅតាមរយៈពិពិធកម្មផលិតកម្មក្នុងដំណាក់កាលបន្ទាប់ ការបន្តផ្លាស់ប្តូរតាមរយៈការជំរុញ ឯកទេសកម្ម ដែលផ្តែលលើការអភិវឌ្ឍវិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានិវត្តន៍ ជឿនលឿន។

គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មត្រូវបានរៀបចំឡើងក្នុងគោលបំណង ផ្តល់នៅចក្ខុវិស័យក្របខណ្ឌគោលនយោបាយ ក្របខណ្ឌសម្របសម្រួលការអភិវឌ្ឍ និងការរៀនចំយន្តការស្ថានប័នសម្រាប់ជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្មនៅកម្ពុជាដើម្បីសម្រាប់ចក្ខុវិស័យខាងលើ។

ដើម្បីសំរេចចក្ខុវិស័យ និងគោលបំណងខាងលើ រាជរដ្ឋាភិបាលកំណត់យកគោលដៅចំបង៣ រួមមានការកែប្រែ និងពង្រឹងរចនាសម្ព័ន្ធឧស្សាហកម្ម និងសេដ្ឋកិច្ចជាតិ ការបង្កើន និងពិពិធកម្មមុខទំនិញនាំចេញ និងពង្រឹងយន្តការគ្រប់គ្រង់ និងជំរុញការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម[11]។

ដើម្បីសំរេចនូវចក្ខុវិស័យគោលដៅ និងគោលបំណងខាងលើ យុទ្ធសាស្រ្តគន្លឹះរបស់រាជរដ្ឋាភិបាល ផ្តោតជាសំខាន់លើកការរៀបចំ និងអនុវត្តនៅក្របខណ្ឌគោលនយោបាយមួយច្បាស់លាស់ ដែលមានការសម្របសម្រួលប្រទាក់ក្រឡាគ្នា និងបំពេញគ្នាទៅវិញទៅមកដោយចាប់ផ្តើមពីការកែទម្រង់ និងការសម្រួល ស្ថាប័នដើម្បីធានានូវប្រសិទ្ធិភាព នៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម។ ក្របខណ្ឌគោលនយោបាយនេះមានសសរស្តម្ភបួន (១)ការទាក់ទាញវិនិយោគផ្ទាល់ពីបរទេស និងការកៀរគរវិនិយោគឯកជនក្នុងស្រុកសម្រាប់អភិវឌ្ឍន៍វិស័យ

[10] ឯ.ឧ សារុន បុទ្ធា(រដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម វិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍)

[11] គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥

ឧស្សាហកម្ម ការអភិវឌ្ឍនិងពង្រីកទីផ្សានាំចេញ និងការជំរុញការអភិវឌ្ឍ និងផ្ទេរបច្ចេកវិទ្យា (២)ការអភិវឌ្ឍទំនើបកម្មសហគ្រាសធុនតូច និងមធ្យម ដើម្បីពង្រីកនិងពង្រឹង មូលដ្ឋានឧស្សាហកម្ម កម្មន្តសាល ការធ្វើទំនើបកម្ម និងបញ្ជីសហគ្រាសជាផ្លូវការ ការជំរុញការអភិវឌ្ឍ និងផ្ទេរបច្ចេកវិទ្យា និងការពង្រឹងការតភ្ជាប់ឧស្សាហកម្មរវាងសហគ្រាសក្នុងស្រុកជាមួយសហគ្រាសក្រៅប្រទេស ពិសេសក្នុងវិស័យកសិ-ឧស្សាហកម្ម (៣)ការកែលម្អបរិស្ថាននិយ័តកម្ម ដើម្បីពង្រឹងភាពប្រកួតប្រជែងតាមរយៈការលើកកម្ពស់បរិយាកាសវិនិយោគ និងកិច្ចសម្រួលពាណិជ្ជកម្ម ការផ្តល់ព័ត៌មានអំពីទីផ្សារ (៤)ការសម្របសម្រួល ការអភិវឌ្ឍធនធានមនុស្ស ការបណ្តុះបណ្តាលជំនាញ និងការកែលម្អទំនាក់ទំនងឧស្សាហកម្ម ការអនុវត្តរៀបចំផែនការដែនដី នគរូបនីយកម្ម និងផែនការប្រើប្រាស់ ព្រមទាំងការអនុវត្តហេដ្ឋារចនាសម្ព័ន្ធ រួមមានការតភ្ជាប់ការដឹកជញ្ជូនប្រព័ន្ធឡូជីស្ទីក និងការតភ្ជាប់ឌីជីថល ការផ្គត់ផ្គង់អគ្គិសនី និងទឹកស្អាត ដូចជាសេវាសាធារណៈ សេវាសង្គមកិច្ច និងសេវាហិរញ្ញវត្ថុ[12]។

[12] គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥

# ជំពូកទី២
# រចនាសម្ព័ន្ធគ្រប់គ្រង

រចនាសម្ព័ន្ធគ្រប់គ្រងវិស័យឧស្សាហកម្ម និងសិប្បកម្មនៅព្រះរាជាណាចក្រកម្ពុជាដែល បច្ចុប្បន្នបានប្រែក្លាយទៅជាវិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ មានរចនា សម្ព័ន្ធគ្រប់គ្រង់(១)នៅថ្នាក់ជាតិ (២) នៅថ្នាក់ក្រោមជាតិ

## ២.១ រចនាសម្ព័ន្ធគ្រប់គ្រងថ្នាក់ជាតិ

រចនាសម្ព័ន្ធគ្រប់គ្រងថ្នាក់ជាតិមានន័យថា រចនាសម្ព័ន្ធគ្រប់គ្រងនៅថ្នាក់ក្រសួង គឺ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដឹកនាំដោយរដ្ឋមន្ត្រីមួយរូប ដែលមានខុទ្ទកាល័យមួយជាជំនួយការ អមដោយរដ្ឋលេខាធិការមួយចំនួន (បច្ចុប្បន្នមាន១៤រូប) ក្នុងនោះមានរដ្ឋលេខាធិការជាស្ត្រីមួយរូប និងអនុរដ្ឋលេខាធិការមួយចំនួន(បច្ចុប្បន្ន១៣រូប) ក្នុងនោះមានអនុរដ្ឋលេខាធិការជាស្ត្រីចំនួនពីររូប។ ទន្ទឹមនិងនេះ ក្រសួងក៏មានទីប្រឹក្សា និងជំនួយការមួយចំនួនផងដែរ។ ឋានុក្រមបន្ទាប់ពីថ្នាក់ដឹកនាំ អតីតក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវបានបែងចែកជាប្រាំមួយអង្គភាព (១)អគ្គនាយកដ្ឋានកិច្ចការទូទៅ (២)អគ្គនាយកដ្ឋានឧស្សាហកម្ម (៣)អគ្គនាយកដ្ឋានសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម (៤)វិទ្យាស្ថានស្តង់ដារកម្ពុជា (៥)មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ (៦)អគ្គាធិការដ្ឋាន (៧)នាយកកដ្ឋានសវកម្មផ្ទៃក្នុង (៨)អង្គភាពផលិតកម្ម[13]។

### ២.១.១ អគ្គនាយកដ្ឋានកិច្ចការទូទៅ

អគ្គនាយកដ្ឋានកិច្ចការទូទៅ ដឹកនាំដោយអគ្គនាយកមួយរូប អមដោយអគ្គនាយករងមួយចំនួន មានរចនាសម្ព័ន្ធបែងចែកជាប្រាំនាយកដ្ឋាន (១)នាយកដ្ឋានរដ្ឋបាលដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួន (២)នាយកដ្ឋានបុគ្គល ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួន (៣)នាយកដ្ឋាន គណនេយ្យ និងហិរញ្ញវត្ថុ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួន (៤)នាយកដ្ឋាននីតិកម្ម ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួន (៥)នាយកដ្ឋានផែនការ សិក្តិ សហប្រតិបត្តិការ និងការងារអាស៊ានដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួន [14]។

### ២.១.២ អគ្គនាយកដ្ឋានឧស្សាហកម្ម

អគ្គនាយកដ្ឋានឧស្សាហកម្ម ដឹកនាំដោយអគ្គនាយកមួយរូប អមដោយអគ្គនាយករងមួយចំនួន មានរចនាសម្ព័ន្ធបែងចែកជាប្រាំនាយកដ្ឋាន និងមជ្ឈមណ្ឌលមួយ (១)នាយកដ្ឋានកិច្ចការឧស្សាហកម្ម ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួន (២)នាយកដ្ឋាន បច្ចេកទេស វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដឹកនាំដោយប្រធានមួយ

[13]អង្គការលេខរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

[14] អង្គការលេខរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

រូប និងអនុប្រធានមួយចំនួន (៣)នាយកដ្ឋានទីកស្អាត ដែលក្រោយមកត្រូវបានតំឡើងមកជាអគ្គនាយកដ្ឋានទឹកស្អាត ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួន (៤)នាយកដ្ឋានវាយតម្លៃទទួលស្គាល់ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួន (៥)នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួន (៦)មជ្ឈមណ្ឌលផលិតភាពជាតិ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួន[15]។

### ២.១.៣ អគ្គនាយកដ្ឋានសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម

អគ្គនាយដ្ឋានសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម ដឹកនាំដោយអគ្គនាយកមួយរូប អមដោយអគ្គនាយករងមួយចំនួន មានរចនាសម្ព័ន្ធបែងចែកជាបីនាយកដ្ឋាន (១)នាយកដ្ឋាន សហគ្រាសធុនតូច និងមធ្យម ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួន (២)នាយកដ្ឋានកិច្ចការឧស្សាហកម្ម ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួន (៣)នាយកដ្ឋានផែនការ និងជំរុញការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម ដឹកនាំដោយប្រធានមួយរូប និង អនុប្រធានមួយ ចំនួន[16]។

### ២.១.៤ វិទ្យាស្ថានស្តង់ដារកម្ពុជា

វិទ្យាស្ថានស្តង់ដារកម្ពុជា ដឹកនាំដោយប្រធានមួយរូប ដែលមានឋានៈស្មើអគ្គនាយក អមដោយអនុប្រធានមួយចំនួន មានរចនាសម្ព័ន្ធបែងចែកជាបួននាយកដ្ឋាន និងមជ្ឈមណ្ឌលមួយ (១)នាយកដ្ឋានព័ត៌មាន ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួន (២)នាយកដ្ឋានអភិវឌ្ឍស្តង់ដារ បណ្តុះបណ្តាល និងពិគ្រោះយោបល់ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួន (៣)នាយកដ្ឋានវិញ្ញាបនប័ត្រកម្ម ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួន (៤)នាយកដ្ឋានបញ្ញត្តកម្ម ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួន និងមជ្ឈមណ្ឌលមន្ទីរពិសោធន៍កម្ពុជា ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួន[17]។

### ២.១.៥ មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ

មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ដឹកនាំដោយប្រធានមួយរូប ដែលមានឋានៈស្មើអគ្គនាយក អមដោយអនុប្រធានមួយចំនួន មានរចនាសម្ព័ន្ធបែងចែកជាបួននាយកដ្ឋាន (១)នាយកដ្ឋានវិទ្យាសាស្ត្រមាត្រាសាស្ត្រ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួន (២)នាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួន (៣)នាយកដ្ឋានមាត្រាសាស្ត្រឧស្សាហកម្ម ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួន (៤)នាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួន[18]។

[15] អង្គការលេខរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

[16] អង្គការលេខរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

[17] អង្គការលេខរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

[18] អង្គការលេខរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

**២.១.៦ អគ្គាធិការដ្ឋាន**

អគ្គាធិការដ្ឋាន ដឹកនាំដោយអគារធិការមួយរូប អមដោយអគ្គាធិការរងមួយចំនួន និងអធិការមួយចំនួន[19]។

**២.១.៧ នាយកកដ្ឋានសវកម្មផ្ទៃក្នុង**

នាយកកដ្ឋានសវកម្មផ្ទៃក្នុង ដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយចំនួន។[20]

**២.១.៨ អង្គភាពផលិតកម្ម**

អង្គភាពផលិតកម្ម ដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយចំនួន។

បន្ថែមពីលើអង្គភាពទាំងប្រាំបីរបស់អតីតក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រោយពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍ ក៏មានអង្គភាពថ្មីចំនួនពីរត្រូវបានបង្កើតឡើងស្របពេលជាមួយគ្នានេះដែរគឺ (១)អគ្គនាយកដ្ឋានវិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍ ដែលទទួលបន្ទុកលើគោលនយោបាយ និង (២)វិទ្យាស្ថាន វិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍ ដែលទទួលបន្ទុកលើការងារស្រាវជ្រាវ និងអភិវឌ្ឍន៍។ បច្ចុប្បន្ន អង្គភាពថ្មីទាំងពីរកំពុងរៀបចំរចនាសម្ព័ន្ធផ្ទៃក្នុងរបស់ខ្លួននៅឡើយដោយត្រូវបែងចែកជានាយកដ្ឋានបច្ចេកទេស និងជំនាញផ្សេងៗ នៅពេលអនាគត។ ទន្ទឹមនិងនេះគ្រប់នាយកដ្ឋាននៃអង្គភាពទាំងអស់ក៏ត្រូវបែងចែកជាការការិយាល័យ ឯកទេស និងជំនាញជាច្រើនដែលចំពោះការសិក្សានេះសូមអនុញ្ញាតមិនចូលលម្អិតដល់កម្រិតនេះទេព្រោះការិយាល័យនីមួយៗ មានប្រធានមួយរូប អនុប្រធានមួយចំនួន និងមន្រ្តីមួយចំនួនផងដែល[21]។

## ២.២ រចនាសម្ព័ន្ធគ្រប់គ្រងថ្នាក់ក្រោមជាតិ

រចនាសម្ព័ន្ធគ្រប់គ្រងថ្នាក់ក្រោមជាតិ ត្រូវបានបែងចែកជាពីរប្រភេទគឺ (១)មន្ទីរឧស្សាហកម្ម និងសិប្បកម្ម ដែលបច្ចុប្បន្នបានប្រែក្លាយទៅជាមន្ទីរឧស្សាហកម្ម វិទ្យាសាស្រ្ត បច្ចេវិទ្យា និងនវានុវត្តន៍ទាំង២៥ រាជធានីខេត្តនិង (២)អង្គភាពរដ្ឋាទឹកនៅតាមបណ្តាខេត្ត និងរាជធានីភ្នំពេញ ដែលក្នុងនោះមានអង្គភាព រដ្ឋាទឹកស្វយ័តរាជធានីភ្នំពេញ និងរដ្ឋាទឹកស្វយ័តសៀមរាប មន្ទីរឧស្សាហកម្ម វិទ្យាសាស្រ្ត បច្ចេវិទ្យា និងនវានុវត្តន៍ រាជធានី ខេត្តទាំង២៥ ដឹកនាំដោយប្រធានមួយរូប ដែលមាន ឋានៈស្មើអនុប្រធាននាយកដ្ឋាន អមដោយអនុប្រធានមួយចំនួន ហើយត្រូវបានបែងចែកជាការិយាល័យបច្ចេកទេស និងជំនាញផ្សេងៗដូចជា ការិយាល័យរដ្ឋបាល ការិយាល័យឧស្សាហកម្ម ការិយាល័យសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម ការិយាល័យស្តង់ដារ និងការិយាល័យមាត្រាសាស្រ្ត។ មុនកំណែទម្រង់ស៊ីជម្រៅវិមជ្ឈការ និងវិសហមជ្ឈការនៅតាមបណ្តា ក្រុង ស្រុក ខណ្ឌ មានការិយាល័យឧស្សាហកម្ម និងសិប្បកម្មចំណុះឲ្យមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានីខេត្ត។ ក្រោយពីកំណែទម្រង់ស៊ីជម្រៅនេះមក ការិយាល័យជំនាញទាំងអស់ ដែលជាខ្សែ បណ្តោយរបស់រាជរដ្ឋាភិបាលត្រូវបានរំសាយចោល ដោយជំនាញទាំងអស់នោះ ត្រូវបានទៅ

[19] អង្គការលេខរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

[20] អង្គការលេខរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

[21] អង្គការលេខរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

ប្រមូលផ្តុំនៅច្រកចេញចូលតែមួយនៅឯសាលារាជធានីខេត្តវិញ លើកលែងតែការិយាល័យសុខាភិបាល ការិយាល័យអប់រំយុវជននិងកីឡា ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ដែលត្រូវបានរក្សាទុករចនាសម្ព័ន្ធដដែលនៅតាមក្រុង ស្រុក ខណ្ឌ។

# ជំពូកទី៣
# របកគំហើញក្នុងការគ្រប់គ្រង

## ៣.១ លទ្ធផលការងារតាមវិស័យជំនាញ

### ៣.១.១ វិស័យឧស្សាហកម្ម

#### ៣.១.១.១ កិច្ចការឧស្សាហកម្ម

ក្នុងគោលបំណងអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាប្រកបដោយនិរន្តរភាព ធានាបានសុខដុមនីយកម្មសង្គម និងបរិស្ថានក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានសម្រេចការងារដូចខាងក្រោម៖

ក. ការចុះបញ្ជីរោងចក្រ

ក្នុងឆ្នាំ២០១៩ មានរោងចក្រកើនថ្មីចំនួន ២៦៩រោងចក្រ ធៀបនិងឆ្នាំ២០១៨ ដែលមានរោងចក្រកើនថ្មីត្រឹមតែ១៩៨រោងចក្រ។ រោងចក្រស្ថិតក្រោមការគ្រប់គ្រង់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្មមានចំនួន១,៧៣០រោងចក្រ នៃឆ្នាំ២០១៨ ក្នុងនោះមានកំណើនខ្លាំងទៅតាមផ្នែកសំខាន់ៗមួយចំនួន ដូចជា ផ្នែកអាហារ ភេសជ្ជៈ បារី មានចំនួន ១៥៧រោងចក្រ ផ្នែកឧស្សាហកម្មតម្បាញ កាត់ដេរ ចាក់សម្លៀកបំពាក់ កាបូប និងស្បែកជើង មានចំនួន ១,០៦៩រោងចក្រ ផ្នែកផលិតកម្មពីក្រដាស និងបោះពុម្ពផ្សេងៗ (លើកលែងបោះពុម្ពលើសម្លៀកបំពាក់) មានចំនួន ៥៩រោងចក្រ ផ្នែកឧស្សាកម្មគីមី កៅស៊ូ និងប្លាស្ទិក មានចំនួន ១៤៣រោងចក្រ ផ្នែកឧស្សាហកម្មពីរ៉ែ មិនមែនលោហៈ មានចំនួន ៥០រោងចក្រ ផ្នែកឧស្សាហកម្មកែច្នៃលោហៈ មានចំនួន ១៤៥រោងចក្រ ផ្នែកគ្រឿងសង្ហារឹម ឧស្សាហកម្មពីឈើ និងផលិតផលពីឈើ មានចំនួន ៥៤រោងចក្រ និងផ្នែកឧស្សាហកម្មផ្សេងៗទៀតមាន ចំនួន៥៣រោងចក្រ[22]។

ក្នុងឆ្នាំ២០១៩ ក្រៅពីការនាំចេញប្រកាសបង្កើតរោងចក្រ ក្រសួងក៏បានផ្តល់លិខិតអនុញ្ញាតផ្សេងៗដូចជា វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រចំនួន២១៥ច្បាប់ បន្ត សុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ចំនួន២១៥ច្បាប់ ប្តូរប្រកាសទម្រង់ថ្មីជូន រោងចក្រ ចំនួន១៣០ច្បាប់ លិខិតអនុញ្ញាតប្តូរទីតាំងរោងចក្រ ចំនួន ០៦ច្បាប់ លិខិតអនុញ្ញាតប្តូរប្រធានក្រុមប្រឹក្សាភិបាល និងប្តូរអភិបាលរោងចក្រ ចំនួន៤០ច្បាប់ លិខិតអនុញ្ញាតប្តូរនាមករណ៍រោងចក្រ ចំនួន០២ច្បាប់ លិខិតអនុញ្ញាតចុះបញ្ជីរោងចក្រ ចំនួន០២ច្បាប់ និងលិខិតអនិញ្ញាតពង្រីកទីតាំងផលិកម្មចំនួន១៧ច្បាប់ [23] ។ នៅចំពោះមុខការរីកលូតលាស់យ៉ាងឆាប់រហ័សនៃវិស័យឧស្សាហកម្ម ទោះបីជាឧស្សាហកម្មកាត់ដេរនៅតែនាំមុខ ប៉ុន្តែផ្នែកទិន្នន័យខាងលើ ជាកញ្ចក់ឆ្លុះបញ្ចាំងឲ្យឃើញថា វិស័យឧស្សាហកម្មនៅកម្ពុជាកំពុងធ្វើពិពិធកម្មយ៉ាងពិប្រាកដ ដោយមានលេចឡើងនៅឧស្សាហកម្មថ្មីៗ ដែលមានតម្លៃបន្ថែមខ្ពស់ និងប្រើប្រាស់បច្ចេកវិទ្យាទំនើប ដូចជារោងចក្រតម្លើងរថយន្ត-ម៉ូតូ រោងចក្រផលិតគ្រឿងបន្លាស់ និងគ្រឿងសន្សំយាន

[22] របាយការណ៍ បូកសរុបលទ្ធផលការងាររបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប្រចាំឆ្នាំ២០១៩ និងទិសដៅការងារឆ្នាំ២០២០

[23] របាយការណ៍ បូកសរុបលទ្ធផលការងាររបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប្រចាំឆ្នាំ២០១៩ និងទិសដៅការងារឆ្នាំ២០២០

យន្ត-ម៉ូតូ គ្រឿងបង្គុំអេឡិចត្រូនិក បរិក្ខាអគ្គិសនី សម្ភារៈសំណង់ រោងចក្រកែច្នៃផលិតផលកសិ-ឧស្សាហកម្ម ។ល។ ដែលឧស្សាហកម្មប្រភេទនេះមានតិចតួចបំផុតក្នុង រយៈពេល៥ឆ្នាំមុន។

ខ. តម្លៃសរុបបរិមាណផលិតផល

តម្លៃសរុបបរិមាណផលិតផលក្នុងឆ្នាំ២០១៩ មានចំនួន ១៤,៨៧៥លានដុល្លារអាមេរិក កើនឡើងក្នុងរង្វង់ ១៣% ក្នុងនោះឧស្សាហកម្មបម្រើទីផ្សារក្នុងស្រុកមានចំនួន៣,៦៩០លានដុល្លារ អាមេរិក និងឧស្សាហកម្មនាំចេញ (ផលិតផលសម្លៀកបំពាក់ កាបូប និងស្បែកជើង) មានចំនួន៩,៣២៥លានដុល្លារអាមេរិក និងឧស្សាហកម្មនាំចេញផ្សេងៗទៀត(ផលិតផល អង្ករ ស្ករស ចំណីសត្វ កង់ កេស កាតុង កំប៉ុងស្រាបៀរ ស្រាបៀរ ភេសជ្ជៈ បារី ប្រដាប់ព្យួរសម្លៀកបំពាក់ ត្បូងពេជ្រ ខ្សែរូត សម្ភារកីឡា សម្ភារៈក្មេងលេង សម្ភារៈប្លាស្ទិក ក្រណាត់តង់ គ្រឿងសំអាង គ្រឿងសង្ហារឹម អេតាណុល សម្ភារៈអគ្គិសនី) មានចំនួន ១,៨៦០លានដុល្លារអាមេរិក កើនឡើង២៧%បើប្រៀបធៀបនឹងឆ្នាំ ២០១៨[24]។

**៣.១.១.២ ការងារកម្មសិទ្ធិឧស្សាហកម្ម**

ក. ការងារបញ្ញត្តិកម្ម

(១)ចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា ស្តីពីសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម រវាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងអង្គភាពកម្មសិទ្ធិបញ្ញាកូរ៉េ នៃសាធារណរដ្ឋកូរ៉េ (២)ប្រកាសលេខ ២២៨ MIH/2019 ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្តីពីការពន្លឿនការផ្តល់ប្រកាសនីយបត្រតក្កកម្មកម្ពុជា ទាក់ទងទៅនិងពាក្យសុំប្រកាសនីយបត្រតក្កកម្ម ជាមួយអង្គភាពកម្មសិទ្ធិបញ្ញាកូរ៉េ នៃសាធារណរដ្ឋកូរ៉េ (៣)ចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា រវាងអង្គភាពកម្មសិទ្ធិបញ្ញាកូរ៉េ នៃសាធារណរដ្ឋកូរ៉េ និងក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្តីពីការទទួលស្គាល់អង្គភាពកម្មសិទ្ធិបញ្ញា នៃសាធារណរដ្ឋកូរ៉េ ជាអាជ្ញាធរស្រាវជ្រាវអន្តរជាតិ និងអាជ្ញាធរត្រួតពិនិត្យ អន្តរជាតិដំបូង ក្រោមកិច្ចសហប្រតិបត្តិការសន្ធិសញ្ញាប្រកាសនីយបត្រតក្កកម្ម សម្រាប់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម[25]។

ខ. ការចុះបញ្ជី

ក្នុងឆ្នាំ២០១៩ ការងារចុះបញ្ជីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមាន អត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ទទួលបានលទ្ធផលដូចជា៖ (១)ទទួលសំណុំលិខិតស្នើសុំផ្តល់ប្រកាសនីយបត្រតក្កកម្មថ្មី សរុបចំនួន ១០២សំណុំលិខិត និងផ្តល់ប្រកាសនីយបត្រតក្កកម្មថ្មី ចំនួន០៦សំណុំលិខិត (២)ទទួលសំណុំលិខិតស្នើសុំផ្តល់ប្រកាសនីយបត្រតក្កកម្មសារឡើងវិញពីប្រទេសសឹង្ហបូរី ចំនួន១៩ និងទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មសាឡើងវិញពីប្រទេសសឹង្ហបូរី ចំនួន០៦ សំណុំលិខិត (៣)ទទួលសំណុំលិខិតស្នើសុំចុះបញ្ជីសាឡើងវិញនៃប្រកាសនីយបត្រ

[24] របាយការណ៍ បូកសរុបលទ្ធផលការងាររបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប្រចាំឆ្នាំ២០១៩ និងទិសដៅការងារឆ្នាំ២០២០

[25] របាយការណ៍ បូកសរុបលទ្ធផលការងាររបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប្រចាំឆ្នាំ២០១៩ និងទិសដៅការងារឆ្នាំ២០២០

តក្កកម្មចិន នៅកម្ពុជាចំនួន១៨៨ និងទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មចិនសាឡើងវិញ ចំនួន៦៩ (៤)ទទួលស្គាល់សំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្មថ្មី សរុបចំនួន១៤៣សំណុំលិខិត (៥)ចុះបញ្ជីគំនូរឧស្សាហកម្មសារឡើងវិញបាន ចំនួន៧១សំណុំលិខិត(៦)ទទួលស្គាល់លិខិតតាមប្រព័ន្ធហោក បានចំនួន៥៨សំណុំលិខិត[26]។

### ៣.១.២ វិស័យសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម

#### ៣.១.២.១ សហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម

ចាប់ពីខែមករា ដល់ចុងខែធ្នូ ឆ្នាំ២០១៩ មានមូលដ្ឋានបង្កើតថ្មីកើន ៥១មូលដ្ឋាន បន្តចំនួន៦២ មូលដ្ឋាន និងពលកម្មកើន ៦៦២នាក់។ គិតត្រឹមដំណាច់ខែធ្នូ ឆ្នាំ២០១៩ មានមូលដ្ឋានសរុប៥២,១៥៤មូលដ្ឋាន និងពលកម្មសរុប ៨២៤,២៨៥នាក់[27]។

#### ៣.១.២.២ ការងារជំរុញ និងអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម

ដើម្បីធានាឲ្យបានការគ្រប់គ្រង និងអភិវឌ្ឍវិស័យសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម មានប្រសិទ្ធិភាពល្អប្រសើរ ក្រសួងបានខិតខំជំរុញការងារកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ការបណ្តុះបណ្តាល និងការងារគ្រប់គ្រងទិន្នន័យពាក់ព័ន្ធវិស័យនេះដូចជា (១)រៀបចំគោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍវិស័យសហគ្រាសធុនតូច និងមធ្យម (២)បង្កើតគោលការណ៍កំណត់ផលិតផលកម្ពុជាមានគុណភាពខ្ពស់ ដើម្បីជំរុញការប្រកួតប្រជែងក្នុងផលិតកម្ម ការលើកកម្ពស់ផលិតផល និងការធ្វើពាណិជ្ជកម្មលើទីផ្សារផលិតផលកម្ពុជា (៣)រៀបចំអនុក្រឹត្យ ស្តីពីការបង្កើត និងគ្រប់គ្រងសួនសហគ្រាសធុនតូច និងមធ្យម (៤)សេចក្តីសំរេចបង្កើតក្រុមការងារជំរុញចលនាភូមិមួយផលិតផលមួយ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម (៥)ចុះអនុស្សរណៈយោគយល់គ្នាជាមួយ អង្គការ NOMI ស្តីពីការគាំទ្រនិងពង្រឹងសមត្ថភាពសហគ្រាសធុនតូច និងមធ្យមលើវិស័យកាត់ដេរ តាមរយៈកិច្ចគាំទ្រកម្មវិធីបណ្តុះបណ្តាលដល់សិប្បករកាត់ដេរសម្លៀកបំពាក់ (៦)ចងក្រងសៀវភៅសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្មដែលបានចុះបញ្ជី (៧)បោះពុម្ពសៀវភៅឆ្នាំ សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា (៨)រៀបចំគ្រប់គ្រងទិន្នន័យសហគ្រាសធុនតូច និងមធ្យម និង សិប្បកម្មតាមរយៈប្រព័ន្ធ Database (៩)រៀបចំចងក្រងសៀវភៅទិន្នន័យនៃសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម តាមមូលដ្ឋានរាជធានី ខេត្ត (១០)ក្រសួងបានធ្វើប្រត្តិភូកម្មមុខងារ ដល់ថ្នាក់ក្រោមជាតិ (ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមន្ទីរជំនាញ) សំដៅធ្វើឲ្យការផ្តល់សេវាពាក់ព័ន្ធ និង វិស័យឧស្សាហកម្ម និងសិប្បកម្ម ត្រូវបានពង្រាយ និងបង្កិតជិតទៅដល់អ្នកដែលត្រូវការសេវា ដោយអនុវត្តតាមគោលការណ៍ តម្លាភាព គណនេយ្យភាព ប្រសិទ្ធិភាព និងឆាប់រហ័ស[28]។

[26] របាយការណ៍ បូកសរុបលទ្ធផលការងាររបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប្រចាំឆ្នាំ២០១៩ និងទិសដៅការងារឆ្នាំ២០២០

[27] របាយការណ៍ បូកសរុបលទ្ធផលការងាររបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប្រចាំឆ្នាំ២០១៩ និងទិសដៅការងារឆ្នាំ២០២០

[28] ឯកឧត្តម សារុន បុទ្ធា(រដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍)

### ៣.១.៣ វិស័យទឹកស្អាត

ដើម្បីសំរេចគោលដៅយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងវិស័យទឹកស្អាត ដែលបានកំណត់ ឆ្នាំ២០២៥ គឺប្រជាជន១០០% នៅទីប្រជុំជនត្រូវមានទឹកស្អាតប្រើប្រាស់ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានយកចិត្តទុកដាក់អនុវត្តកិច្ចការនេះយ៉ាងសកម្ម ទទួលលទ្ធផលគិតត្រឹមដំណាច់ខែធ្នូ ឆ្នាំ២០១៩មាន៖ (១)ការផ្គត់ផ្គង់ទឹកស្អាតសាធារណៈ និងឯកជន សរុបបានចំនួន ៣៣១,៦១៤,២៥៦ម៣ (២)បណ្តាញទុយោចែកចាយទឹកសរុប គិតមកដល់ចុងឆ្នាំ២០១៩ តាមបណ្តាអង្គភាពរដ្ឋាទឹកសាធារណៈនិងឯកជនទូទាំងប្រទេសរួមមានប្រវែង៧៣,៨៣០.២៧គីឡូម៉ែត្រ[29]។ ដោយឡែកក្នុងនោះអង្គភាពរដ្ឋាទឹកសាធារណៈ ១១ខេត្ត ក្រុង មានបណ្តាញមេ និងបណ្តាញចែកចាយសរុបប្រវែង ១,៧៦៦.៧២គីឡូម៉ែត្រ (៣)កំពុងរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីការគ្រប់គ្រងការផ្គត់ផ្គង់ទឹកស្អាតសាធារណៈ និងឯកជនសំរេចឲ្យបានតាមគោលដៅនៃការផ្គត់ផ្គង់ទឹកស្អាត នៅទីក្រុង និងទីប្រជុំជនឲ្យបាន៩០% ត្រឹមឆ្នាំ២០២៣ និង១០០% ត្រឹមឆ្នាំ២០២៥ ដោយឈរលើបុរេលក្ខខណ្ឌបួនយ៉ាងគឺ **"ទឹកត្រូវមានគុណភាព សុវត្ថិភាព និរន្តភាព និងតម្លៃសមរម្យ"** សំដៅធានាទាំងផលប្រយោជន៍គ្រប់ភាគីរួមមានភាគីរដ្ឋាភិបាល ភាគីអ្នកផ្តល់សេវា និងជាពិសេសភាគីប្រជាជន ដោយជួយឧបត្ថម្ភធនដល់ប្រជាជនក្រីក្រ (៤)ធ្វើកំណែទម្រង់ក្នុងការផ្គត់ផ្គង់ទឹកស្អាត ដល់ប្រជាជននៅ ឃុំ សង្កាត់ ភូមិ ដែលពុំទាន់មានប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ហើយដោយរដ្ឋពុំទាន់មានលទ្ធភាពធ្វើបាន ដោយផ្តល់សិទ្ធិធ្វើអាជីវកម្មរហូតដល់២០ឆ្នាំ ដែលពីមុនអនុញ្ញាតឲ្យត្រឹមតែ៣ឆ្នាំ ដើម្បីធានាបាននិរន្តភាពនៃការផ្គត់ផ្គង់ទឹកស្អាត និងពង្រីកផ្ទៃសេវាផ្គត់ផ្គង់ឲ្យបាន លឿន។ ក្រសួងបានយកចិត្តទុកដាក់រៀបចំ និងកែសម្រួលកម្មវិធី និងលិខិតបទដ្ឋានគតិយុត្តចាំបាច់មួយចំនួនថែមទៀតសំដៅគ្រប់គ្រង និងអភិវឌ្ឍន៍វិស័យទឹកស្អាតឲ្យកាន់តែមានសន្ទុះកើនឡើង និងមានប្រសិទ្ធិភាពជាងពេលមុន ជាពិសេសគឺទាក់ទាញការចូលរួមវិនិយោគពីផ្នែកឯកជន (៥)អនុវត្តគោលនយោបាយផ្គត់ផ្គង់ទឹកស្អាតដល់គ្រួសារក្រីក្រមានចំណូលទាប ព្រមទាំងបានកែសម្រួលការបញ្ចុះថ្លៃទឹកស្អាត និងតភ្ជាប់បណ្តាញទឹកស្អាតជូនកម្មករ-កម្មការិនី និងសិស្ស-និស្សិតស្នាក់នៅបន្ទប់ជួលនៅរាជធានីភ្នំពេញ ដោយបានចុះកិច្ចសន្យាជាមួយម្ចាស់ផ្ទះជួលសម្រាប់ការផ្គត់ផ្គង់ ទឹកស្អាតក្នុងតម្លៃ ៧០០៛/ម៣ ហើយម្ចាស់ផ្ទះជួលអាចលក់ចេញបានក្នុងតម្លៃ៨០០៛/ម៣[30]។ក្រសួងក៏បានបន្តតាមដានជាប់ជាប្រចាំការងារអនុវត្តប្រកាស និងការធ្វើអាជីវកម្មទឹកស្អាតរបស់ប្រតិបត្តិករទឹកស្អាតតាមបណ្តារាជធានី ខេត្តទូទាំងប្រទេស ដោយចាត់តាំងមន្ត្រីចុះសិក្សាត្រួតពិនិត្យ លើស្ថានភាពអាជីវកម្ម និងលក្ខណៈបច្ចេកទេស ក្នុងនោះបានចុះត្រួតពិនិត្យ និងតាមដានការអនុវត្តប្រកាស បានចំនួន២២ ចុះត្រួតពិនិត្យទីតាំងស្ថានីយ៍ផ្គត់ផ្គង់ទឹកស្អាតឯកជន ដើម្បីឈានដល់ការចេញវិញ្ញាបនបត្រប្រតិបត្តិករ បានចំនួន ៣៣ទីតាំង ព្រមទាំងចុះពិនិត្យ និងសម្របសម្រួលដោះស្រាយវិវាទ បានចំនួន៥ទីតាំង។

[29] របាយការណ៍ បូកសរុបលទ្ធផលការងាររបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប្រចាំឆ្នាំ២០១៩ និងទិសដៅការងារឆ្នាំ២០២០

[30] របាយការណ៍ បូកសរុបលទ្ធផលការងាររបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប្រចាំឆ្នាំ២០១៩ និងទិសដៅការងារឆ្នាំ២០២០

### ៣.១.៤ ការងារស្តង់ដារនីយកម្ម

ក្រសួងឧស្សាហកម្ម និងសិប្បកម្មបានយកចិត្តទុកដាក់ និងលើកកម្ពស់កាងារស្តង់ដារ ដើម្បីចូលរួមក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្ម និងសិប្បកម្ម និងសេវាកម្មក៏ដូចជាការខិតខំជំរុញនិងគាំទ្រវាងចក្រ សហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម ឲ្យមានការរីកចម្រើនជាពិសេសបង្កើនប្រសិទ្ធិភាពផលិតកម្ម ធ្វើឲ្យកាន់តែប្រសើរឡើងនូវគុណភាពផលិតផល ធានាបាននូវសុវត្ថិភាពដល់អ្នកប្រើប្រាស់និងលើកកម្ពស់សុខមាលភាពសាធារណៈ ដើម្បីឈានទៅរកការប្រកួតប្រជែងជាមួយផលិតផលនាំចូល។

#### ៣.១.៤.១ ការងារអភិវឌ្ឍស្តង់ដារ

(១)នៅឆ្នាំ២០១៩ ក្រុមប្រឹក្សាស្តរដារជាតិបានប្រជុំចំនួន ២លើក ហើយបានអនុម័តស្តង់ដារជាតិ ចំនួន៥៤ស្តង់ដារ ដែលក្នុងនោះមានស្តង់ដារអនុម័តទទួលយកតាមស្តង់ដារអន្តរជាតិ ISO ផ្នែកប្រព័ន្ធគ្រប់គ្រង ចំនួន១៣ស្តង់ដារ ស្តង់ដារផលិតផលកៅស៊ូ ចំនួន០៥ស្តង់ដារ ស្តង់ដារផលិតផលគីមី ចំនួន០៤ស្តង់ដារអនុម័តទទួលយកតាមស្តង់ដារអន្តរជាតិ IEC ផ្នែកអគ្គីសនី និងអេឡិចត្រូនិច ចំនួន២៨ស្តង់ដារ ស្តង់ដារកូដិច ចំនួន០១ ស្តង់ដារយានយន្តចំនួន១ ស្តង់ដារអាស៊ានចំនួន០៥ ស្តង់ដារអាមេរិកតាមវិធីសាស្ត្រ Endorsement និងស្តង់ដារស្វាយកែវរមៀតចំនួន០១ (២) បានចេញប្រកាស ស្តីពីការបង្កើតស្តង់ដារជាតិ ដែលរួមមានៈ ស្តង់ដារកម្ពុជាផ្នែកសារធាតុ និងផលិតផលគីមី, ស្តង់ដារកម្ពុជាផ្នែកប្រព័ន្ធគ្រប់គ្រង ស្តង់ដារកម្ពុជាផ្នែកផលិតផលអគ្គីសនី និងអេឡិចត្រូនិច ស្តង់ដារកម្ពុជាផ្នែកផលិតផលកៅស៊ូ ស្តង់ដារកម្ពុជាផ្នែកផលិតផលគ្រឿងយន្តបញ្ញាតិរួមដែលពាក់ព័ន្ធ និងការអនុម័តយកឧបករណ៍ព្រមានដោយសញ្ញា ជាសំឡេងសម្រាប់យានយន្ត ប្រកាសទទួលស្គាល់ស្តង់ដារ និងបទប្បញ្ញតិបច្ចេកទេសផ្នែកយានយន្តរបស់សហរដ្ឋអាមេរិកសម្រាប់ការអនុវត្តកិច្ចព្រមព្រៀងក្រមខ័ណ្ឌពាណិជ្ជកម្មនិងវិនិយោគកម្ពុជា_អាមេរិក[31]។

#### ៣.១.៤.២ ការងារវិញ្ញាបនបត្រកម្ម

ការងារវិញ្ញាបនបត្រកម្ម ដើរតួនាទីសំខាន់ក្នុងការវាយតម្លៃភាពអនុលោមតាមស្តង់ដារផលិតផល និងស្តង់ដារប្រព័ន្ធ។ ប្រព័ន្ធចេញវិញ្ញាបនបត្រនេះត្រូវបានរៀបចំ ដោយអនុលោមតាមការតម្រូវនៃស្តង់ដារអន្តរជាតិ សម្រាប់អង្គភាពចេញវិញ្ញាបនបត្រផលិតផល ដំណើរការ និងសេវាកម្ម និងតាមការតម្រូវស្តង់ដារសម្រាប់អង្គភាពនានាដែលផ្តល់នូវការធ្វើសវនកម្ម និងវិញ្ញាបនបត្រលើប្រព័ន្ធគ្រប់គ្រង។ វិញ្ញាបនបត្រ និងអាជ្ញាប័ណ្ណប្រើសញ្ញាស្តង់ដារកម្ពុជាដែលចេញដោយក្រសួងឧស្សាហកម្ម និងសិប្បកម្មមានការទទួលស្គាលកម្រិតជាតិជាតំបន់ និងអន្តរជាតិ លើគុណភាព សុវត្ថិភាព និងសេវាកម្ម ព្រមទាំងកសាងទំនុកចិត្តពីអតិថិជននិងជួយសម្រួលដល់ការធ្វើពាណិជ្ជកម្មក្នុងនិងក្រៅប្រទេស។

[31] របាយការណ៍ បូកសរុបលទ្ធផលការងាររបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប្រចាំឆ្នាំ២០១៩ និងទិសដៅការងារឆ្នាំ២០២០

### ៣.១.៥ ការងារមាត្រាសាស្ត្រជាតិ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានយកចិត្តទុកដាក់អភិវឌ្ឍកាងារមាត្រាសាស្ត្រ តាមរយៈការពង្រឹងក្របខ័ណ្ឌស្ថាប័ន និងសមត្ថភាពមន្ត្រី ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងគោលបំណងលុបបំបាត់របាំងបច្ចេកទេស ដើម្បីឲ្យមានសុខដុមនីយកម្ម ក្នុងសកម្មភាពពាណិជ្ជកម្ម សុខភាព សុវត្ថិភាព និងបរិស្ថាន។ ជាមួយគ្នានេះ ក្រសួងបានខិតខំប្រឹងប្រែងបន្តរៀបចំក្របខ័ណ្ឌគតិយុត្ត និងសិក្សាស្រាវជ្រាវនីតិវិធីត្រួតពិនិត្យ ផ្ទៀងផ្ទាត់ព្យាសនកម្ម តេស្តវិភាគ និងអនុម័តឧបករណ៍មាត្រាសាស្ត្រ ដែលបម្រើឲ្យវិស័យឧស្សាហកម្ម និងសិប្បកម្ម ដោយទទួលបានលទ្ធផលក្នុងឆ្នាំ២០១៩មាន៖ (១) បង្កើនសមត្ថភាពមន្ទីរពិសោធន៍មាត្រាសាស្ត្រឲ្យទទួលបានស្តង់ដារ ISO/IEC 17025 (២)ត្រួតពិនិត្យផ្ទៀងផ្ទាត់ជញ្ជីងតោនចំនួន១៦១គ្រឿង និងស៊ីទែនរថយន្ត១០១គ្រឿង (៣)គិតមកដល់ដំណាច់ឆ្នាំ២០១៩ សម្រាប់ផ្នែកស្ថានីយ៍ដេប៉ូប្រេងឥន្ធនៈ ការចុះបញ្ជីមាត្រាសាស្ត្រថ្មី បានចំនួន២៦២៤មូលដ្ឋាន និងបន្តសុពលភាពបាន ចំនួន១៥១៥មូលដ្ឋាន (៤)ចេញអាជ្ញាប័ណ្ណប្រើពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជា ចំនួន១អាជ្ញាប័ណ្ណ និងបានចេញអាជ្ញាប័ណ្ណផលិត និងជួសជុលឧបករណ៍មាត្រាសាស្ត្រ ជូនក្រុមហ៊ុន ចំនួន២ (៥)ធ្វើការផ្សព្វផ្សាយ និងរៀបចំសិក្ខាសាលា វគ្គបណ្តុះបណ្តាលនៅតាមមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្ត ដោយមានការចូលរួមពីអាជ្ញាធរដែនដី អាជីវកម្ម ម្ចាស់សហគ្រាស អាជីវកម្មនានា ដើម្បីផ្សព្វផ្សាយ និងពង្រឹងច្បាប់ ស្តីពីមាត្រាសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ រួមនិងការចុះបង្ហាត់បង្ហាញ និងអនុវត្តជាក់ស្តែងលើការងារត្រួតពិនិត្យដៃបាញ់ប្រេង ការត្រួតពិនិត្យទំនិញវេចខ្ចប់ និងការត្រួតពិនិត្យជញ្ជីងមិនស្វ័យប្រវត្តិ[32]។

ក្រៅពីកាងារខាងលើ ក្រសួងក៏បានយកចិត្តទុកដាក់ និងការកសាងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដូចជា (១) ពង្រឹងប្រសិទ្ធិភាពក្នុងការចុះអនុវត្តច្បាប់ស្តីពីមាត្រាសាស្ត្រ និងបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យមាត្រាសាស្ត្រ ក្នុងគោលបំណងធានាបាននូវភាពយុត្តិធម៌ សុក្រឹតភាព សមធម៌ ក្នុងការធ្វើពាណិជ្ជកម្ម និងក្នុងជីវភាពសង្គម តាមរយៈមន្ត្រីត្រួតពិនិត្យការងារមាត្រាសាស្ត្រដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ (២)ពង្រឹងការងារមាត្រាសាស្ត្រតាមរយៈការចេញប្រកាស សេចក្តីសំរេច និងការធ្វើបច្ចុប្បន្នភាពប្រកាសស្តីពីការបង្កើតគណៈកម្មាធិការវាយតម្លៃទទួលស្គាល់ជំនាញមាត្រាសាស្ត្រក៏ដូចជាការរៀបចំសេចក្តីព្រាងសារាចរអន្តរក្រសួងស្តីពីទម្រង់ឯកសារសម្រាប់មន្ត្រីត្រួតពិនិត្យការងារមាត្រាសាស្ត្រដែលមាននីតិសម្បទាជានគរបាលយុត្តិធម៌[33]។

### ២.១.៦ ផ្នែកកិច្ចការទូទៅ

#### ២.១.៦.១ ការងារនីតិកម្ម

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានយកចិត្តទុកដាក់លើការកែសម្រួល និងបង្កើតក្របខ័ណ្ឌគតិយុត្ត និងបទប្បញ្ញត្តិគាំទ្រដែលពាក់ព័ន្ធ សំដៅដឹកនាំ និងគ្រប់គ្រងវិស័យជំនាញរបស់ក្រសួងឲ្យកាន់តែមានប្រសិទ្ធិភាព មាន៖

[32] របាយការណ៍ បូកសរុបលទ្ធផលការងាររបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប្រចាំឆ្នាំ២០១៩ និងទិសដៅការងារឆ្នាំ២០២០

[33] សារុន បូទ្ធា(រដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍)

(១)រៀបចំសេចក្តីព្រាងច្បាប់ ស្តីពីការអភិវឌ្ឍ វិស័យសហគ្រាសធុនតូច និងមធ្យម (២)គោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍវិស័យសហគ្រាសធុនតូច និងមធ្យម (៣)អនុក្រឹត្យ ស្តីពីការបង្កើត និងគ្រប់គ្រងសួនសហគ្រាសធុនតូច និងមធ្យម (៤)អនុស្សរណៈយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការរវាងរដ្ឋបាលសម្រាប់និយ័តកម្មទីផ្សាររបស់សាធារណរដ្ឋប្រជាមានិតចិន និងក្រសួងឧស្សាហកម្ម និងសិប្បកម្ម (៥)អនុស្សរណៈយោគយល់គ្នា ស្តីពីសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម រវាងក្រសួហឧស្សាហកម្ម និងសិប្បកម្មនៅព្រះរាជាណាចក្រកម្ពុជា និងអង្គភាពកម្មសិទ្ធិបញ្ញាកូរ៉េ នៃសាធារណរដ្ឋកូរ៉េ (៦)សេចក្តីព្រាងប្រកាសរួមស្តីពីការផ្តល់សិទ្ធិកាពារពូជថ្មីនៃដំណាំនៅកម្ពុជា (៧)សេចក្តីព្រាងប្រកាស ស្តីពីនីតិវិធីណែនាំការចុះបញ្ជីសិទ្ធិអ្នកបង្កាត់ពូជដំណាំ (៨)ការកែសម្រួលឯកសារគតិយុត្តសម្រាប់ធ្វើប្រតិភូកម្មជូនដល់រដ្ឋ បាលថ្នាក់ក្រោមជាតិ (៩)រៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីឯកសណ្ឋាន សញ្ញាសក្តិ និងមួក របស់មន្ត្រីអធិការកិច្ចនៃវិទ្យាស្ថានស្តង់ដារកម្ពុជា (១០)បាន និងកំពុងរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីការគ្រប់គ្រងការផ្គត់ផ្គង់ទឹកស្អាតនៅព្រះរាជាណាចក្រកម្ពុជា[34]។

**៣.១.៦.២ ការងារផែនការ ស្ថិតិ សហប្រតិបត្តិការ និងការងារអាស៊ាន**

(១)រៀបចំផែនការសកម្មភាពទាន់ពេលវេលាតាមដំណាក់កាលនីមួយៗនៃវដ្តផែនការ (២)ផ្តល់ធាតុចូលសម្រាប់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៩-២០២៣ (៣)រៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ និងប្រចាំដំណាក់កាលនីមួយៗនៃការអនុវត្តគោលនយោបាយជាតិប្រជាជន២០១៦-២០៣០ (៤)ចូលរួមបង្កើតសូចនាករគោលសម្រាប់ធ្វើការវាស់វែងពីបម្រែបម្រួលនៃ សូចនាករប្រជាសាស្ត្រសំខាន់ៗ (៥)សហការយ៉ាងជិតស្និទជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយបានផ្តល់នូវទិន្នន័យប្រចាំខែស្តីពីស្ថិតិរោងចក្រសហគ្រាស និងសិប្បកម្ម ដើម្បីរៀបចំជារបាយការណ៍បូកសរុប (៦)ប្រកាន់ខ្ជាប់នូវកាតព្វកិច្ចស្ថិតិស្របតាមស្មារតីនៃអនុក្រឹត្យ ស្តីពីស្ថិតិផ្លូវការ ដោយបានផ្តល់ជូនវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ដែលមាន៖ ស្ថិតិឧស្សាហកម្ម សិប្បកម្ម ប្រចាំខែនិងប្រចាំឆ្នាំស្ថិតិទឹកស្អាតប្រចាំឆ្នាំនិងស្ថិតិការចុះបញ្ជីកម្មឧស្សាហកម្មសិទ្ធិឧស្សាហកម្ម[35]។

**៣.១.៧ ការងាររបស់មន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្ត**

មន្ទីរឧស្សាហកម្ម និងសិប្បកម្មបានធ្វើជាសេនាធិការឲ្យរដ្ឋបាលរាជធានី ខេត្តលើការងារជំនាញក្នុងវិស័យឧស្សាហកម្ម និងសិប្បកម្ម ជាពិសេសក្នុងការងារប្រតិភូកម្ម ដែលក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានធ្វើប្រតិភូកម្មមុខងារជូននូវការងារជំនាញមួយចំនួន ទទួលបានលទ្ធផលមាន៖

**២.១.៧.១ ការងារឧស្សាហកម្ម និងសិប្បកម្ម**

(១)ចុះផ្សព្វផ្សាយច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ព្រមទាំងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម (២)យកចិត្តទុកដាក់ចុះស្រង់ស្ថិតិមូលដ្ឋានរោងចក្រ សហគ្រាស សិប្បកម្ម និង

[34] របាយការណ៍ បូកសរុបលទ្ធផលការងាររបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប្រចាំឆ្នាំ២០១៩ និងទិសដៅការងារឆ្នាំ២០២០

[35] របាយការណ៍ បូកសរុបលទ្ធផលការងាររបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប្រចាំឆ្នាំ២០១៩ និងទិសដៅការងារឆ្នាំ២០២០

អាជីវកម្ម ដើម្បីមានមូលដ្ឋាន រឹងមាំក្នុងការគ្រប់គ្រង (៣) ជំរុញម្ចាស់រោងចក្រ សហគ្រាស សិប្បកម្មនិងអាជីវកម្ម មកចុះបញ្ជី និងសុំច្បាប់អនុញ្ញាត (៤)ចុះត្រួតពិនិត្យ និងណែនាំម្ចាស់រោងចក្រ សហគ្រាស សិប្បកម្ម និងអាជីវកម្ម ឲ្យគោរពតាមបទដ្ឋានបច្ចេកទេស ស្តង់ដារ បរិស្ថាន និងអនាម័យ ដើម្បីធានានូវគុណភាព និងសុវត្ថិភាពដល់អ្នកប្រើប្រាស់ ក៏ដូចជាដើម្បីប្រកួតប្រជែងជាមួយផលិតផលនាំចូលពីបរទេស (៥)ចុះវាយតម្លៃសុវត្ថិភាពឧស្សាហកម្មនៅតាមរោងចក្រ សហគ្រាស ពាក់ព័ន្ធការប្រើប្រាស់គ្រឿងចក្រ គ្រឿងម៉ាស៊ីន ឡចំហាយ ដើម្បីស្នើសុំវិញ្ញាបនបត្របញ្ជាក់ពីសុវត្ថិភាព (៦)ពង្រឹងការត្រួតពិនិត្យគុណភាពផលិតផលឧស្សាហកម្ម ស្បៀង ចំណីអាហារ និងភេសជ្ជៈព្រមទាំងណែនាំសិប្បករ ឧស្សាហករពីការអនុវត្តផលិតផលល្អ (៧)ផ្សព្វផ្សាយការជំរុញការបញ្ចូលសាធាតុអ៊ីយ៉ូតក្នុងអំបិល និងសាធាតុដែកក្នុងទឹកស៊ីអ៊ីវ និងទឹកត្រី[36]។

### ២.១.៧.២ ការងារស្តង់ដារ និងមាត្រាសាស្ត្រ

(១)ផ្សព្វផ្សាយច្បាប់ ស្តីពីស្តង់ដារកម្ពុជា និងច្បាប់ ស្តីពីមាត្រាសាស្ត្រកម្ពុជា (២)ត្រួតពិនិត្យ និងណែនាំការអនុវត្តច្បាប់ ស្តីពីស្តង់ដារកម្ពុជា និងច្បាប់ ស្តីពីមាត្រាសាស្ត្រកម្ពុជា តាមបណ្តា រោងចក្រ សហគ្រាស និងសិប្បកម្ម (៣)ជំរុញ និងណែនាំបណ្តាមូលដ្ឋានផលិត កែច្នៃស្បៀង ភេសជ្ជៈ និងម្ហូបអាហារ ឲ្យធានាបានបរិមាណ គុណភាព និងអនាម័យអនុលោមតាមស្តង់ដារ និងដាក់ពាក្យស្នើសុំប្រើប្រាស់សញ្ញាស្តង់ដារកម្ពុជា (៤)ជំរុញការចុះបញ្ជីផលិតផល (៥)ជំរុញម្ចាស់សិប្បកម្មចំណីអាហារ ទឹកពិសារដប ឲ្យយកសំណាកផលិតផលមកត្រួតពិនិត្យគុណភាពនៅមជ្ឈមណ្ឌលពិសោធន៍ឧស្សាហកម្មកម្ពុជា (៦)ចុះត្រួតពិនិត្យផ្ទៀងផ្ទាត់ចំណុះ(ដៃបាញ់ប្រេង) តាមស្ថានីយប្រេងឥន្ធនៈ និងនៅតាមដេប៉ូ (៧)សហការនៅតាមទីផ្សារនានា ចុះត្រួត ពិនិត្យជញ្ជីងដែលមានសមត្ថភាពក្រោម ១០០០គ.ក (៨)ដាក់ជញ្ជីងយុត្តធម៌ នៅតាមទីផ្សារ និងនៅតាមទីតាំងសំខាន់ៗមួយចំនួន (៩)ចុះត្រួតពិនិត្យ និងណែនាំបណ្តារោងចក្រ និងសិប្បកម្ម ព្រមទាំងបានយកផលិតផលវេចខ្ចប់ មកធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់ បញ្ជាក់ពីបរិមាណ (១០)ចុះត្រួតពិនិត្យ និងណែនាំម្ចាស់រោងចក្រ និងសហគ្រាសឲ្យយកឧបករណ៍មាត្រាសាស្ត្រដែលកំពុងប្រើប្រាស់មកធ្វើព្យាសកម្មនៅមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ និងជំរុញឲ្យមកដាក់ពាក្យស្នើសុំចុះបញ្ជីមាត្រាសាស្ត្រ[37]។

### ២.១.៨ ការងារអគ្គាធិការដ្ឋាន និងសវនកម្មផ្ទៃក្នុង

ដើម្បីធានាបាននូវប្រសិទ្ធិភាពនៃស្ថាប័នសាធារណៈ លើការងារដឹកនាំគ្រប់គ្រង ការងារអធិការកិច្ច និងសវកម្មផ្ទៃក្នុងបានដើរតួនាទីសំខាន់ សម្រាប់តម្រង់ទិសក្នុងការអនុវត្តសកម្មភាពរបស់អង្គភាពជំនាញក្រោមឱវាទក្រសួង សំដៅធ្វើឲ្យការដឹកនាំគ្រប់គ្រងប្រកបដោយតម្លាភាព ស័ក្តិភាព និងគណនេយ្យភាព កាត់បន្ថយការខ្វះខាត ឬឧសឆ្គងក្នុងការងារដឹកនាំ និងគ្រប់គ្រងជាលទ្ធផលទទួលបានមាន៖ (១) ធ្វើអធិការកិច្ច និងសវនកម្មលើការងារដឹកនាំ និងគ្រប់គ្រងរបស់មន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានី ខេត្ត និងបណ្តាអង្គភាពរដ្ឋាទឹកចំណុះមន្ទីរ ដោយ

[36] របាយការណ៍ បូកសរុបលទ្ធផលការងាររបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប្រចាំឆ្នាំ២០១៩ និងទិសដៅការងារឆ្នាំ២០២០

[37] របាយការណ៍ បូកសរុបលទ្ធផលការងាររបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប្រចាំឆ្នាំ២០១៩ និងទិសដៅការងារឆ្នាំ២០២០

រកឃើញប្រតិបត្តិការខ្លះពុំទាន់សុក្រឹត្យភាព ដែលតម្រូវឲ្យមានការកែលម្អ (២)ចុះអធិការកិច្ចត្រួតពិនិត្យរោងចក្របាន ចំនួន៦០៧មូលដ្ឋាន[38]។ ជាលទ្ធផលសង្កេតឃើញថា ការអនុវត្តច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្មការ អនុវត្តស្តីពីមាត្រាសាស្ត្រជាតិនិងការអនុវត្តច្បាប់ស្តីពីស្តង់ដារកម្ពុជាគឺនៅមានកម្រិតនៅឡើយ។

[38] របាយការណ៍ បូកសរុបលទ្ធផលការងាររបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប្រចាំឆ្នាំ២០១៩ និងទិសដៅការងារឆ្នាំ២០២០

# ជំពូកទី៤

# បញ្ហាប្រឈម

ទន្ទឹមនិងសមិទ្ធផលខាងលើ ក្រសួងឧស្សាហកម្ម និងសិប្បកម្មក៏បានជួបប្រទះបញ្ហាប្រឈមមួយចំនួនដូចជា៖

## ៤.១ បញ្ហាធនធានមនុស្ស

កាលការបោះឆ្នោត២០១៣ ពេលដែលអតីតក្រសួងឧស្សាកម្ម រ៉ែ និងថាមពល បានបំបែកទៅជា ក្រសួងឧស្សាងកម្ម និងសិប្បកម្ម និងក្រសួងរ៉ែ និងថាមពល ពេលនោះមន្ត្រីភាគច្រើនបានជ្រើសរើសទៅបម្រើការនៅក្រសួងដែលពួកគេយល់ថាមានអត្ថប្រយោជន៍ច្រើនជាងនៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ពេលនោះអតីតក្រសួងឧស្សាហកម្ម និងសិប្បកម្មបានជួបប្រទះនូវបញ្ហាខ្វះធនធានមនុស្សជាច្រើនជាហេតុនាំឲ្យឯកឧត្តមកត្តិសេដ្ឋាបណ្ឌិតទេសរដ្ឋមន្ត្រីបាន ស្នើសុំមន្ត្រីមកពីក្រសួងពាណិជ្ជកម្មមកជួយបំពេញការងារ ព្រោះមុនពេលគាត់ប្តូរមកក្រសួងឧស្សាហកម្ម និងសិប្បកម្មគាត់ធ្លាប់ធ្វើជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មអស់រយៈពេលដប់ឆ្នាំ[39]។ ទន្ទឹមនិងការខ្វះធនធានមនុស្សរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្មនិងនៅពេលដែលក្រសួងមួយនេះបានពង្រីកវិសាលភាពរបស់ខ្លួនកាលពីខែមីនាឆ្នាំ២០២០នេះ ក្រសួងបង្កើតថ្មីរឹតតែខ្វះធនធានមនុស្សថែមទៀត ជាហេតុនាំឲ្យឯកឧត្តមកត្តិសេដ្ឋាបណ្ឌិតស្នើសុំអ្នកវិទ្យាសាស្រ្តាពីវិទ្យាស្ថានកម្ពុជាមកកាន់តំណែងជាអគ្គនាយក អគ្គនាយករង នៃអគ្គនាយកដ្ឋានដែលទើបបង្កើតថ្មី។ ទោះជាយ៉ាងនេះក្តី អគ្គនាយក អគ្គនាយករង និងប្រធាននាយកដ្ឋានរហូតមកដល់ពេលនេះនៅមិនទាន់មានមន្ត្រីជួយបម្រើការងារនៅឡើយទេ ពោលគឺមានតែប្រធាននាយកដ្ឋានតែគ្មានមន្ត្រី [40] ។ ដោយវិបិត្តកូវីដ-១៩ រាជរដ្ឋាភិបាលដែលមានក្រសួងមុខងារសាធារណៈជាសេនាធិការបានសម្រេចផ្អាកការប្រលងជ្រើសរើសក្របខណ្ឌថ្មីចូលបម្រើការងារគ្រប់ក្រសួង ស្ថាប័នរបស់រដ្ឋទាំងអស់ ដោយរាជរដ្ឋាភិបាលត្រូវទុកថវិកា ដើម្បីដោះស្រាយបញ្ហាកូវិដ ជួយគ្រួសាក្រីក្រ និងស្តារសេដ្ឋកិច្ចចំពោះមុខ។ ដូចនេះ ការដែលក្រសួងដែលទើបពង្រីកវិសាលភាពថ្មី និងគ្របដណ្តប់លើវិស័យវិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍ ហើយខ្វះមន្ត្រីនោះគឺមិនអាចជ្រើសរើសមន្ត្រីប្រចាំឆ្នាំដូចសព្វដងទេ ដែលជាបន្ទុកដល់ធ្ងន់មួយទៀតរបស់ក្រសួង។ កង្វះធនធានមនុស្សដែលមានសមត្ថភាពថវិកាមានកម្រិត មធ្យោបាយក្នុងការ អនុវត្តន៏តាមគម្រោងផែនការចុះបេសកកម្ម វាយតម្លៃ និងតាមដាន ការយកសំណាកគំរូផលិតផលមកពិនិត្យ ការធ្វើព្យាសនកម្មឧបករណ៍ពិសោធន៍ឲ្យស្របតាមស្តង់ដារអន្តរជាតិ និងតាមដានការយកសំណាកគំរូផលិតផលមកពិនិត្យ ការធ្វើព្យាសនកម្មឧបករណ៍ពិសោធន៍ឲ្យស្របតាមស្តង់ដារអន្តរជាតិ និង

[39] សារុន បូទ្ធា(រដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម វិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍)

[40] សារុន បូទ្ធា(រដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម វិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍)

ចុះអធិការកិច្ច[41]។ ការអភិវឌ្ឍវិស័យ សគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម និងតម្រូវការក្នុងវិស័យនេះបានជួបការលំបាកដោយកង្វះ មន្ត្រីមានសមត្ថភាព។ កន្លងមកក្រសួងបានខិតខំដោះស្រាយបានមួយចំនួន តែមិនបានជាប់ជាប្រចាំដោយសារកត្តាផ្សេងៗ ក្នុងនោះកត្តាមធ្យោបាយ និងការពង្រឹងសមត្ថភាពមន្ត្រី។

## ៤.២ បញ្ហាធនធាន

ជាទូទៅគ្រប់ក្រសួងស្ថាប័នរបស់រដ្ឋក្នុងព្រះរាជាណាចក្រកម្ពុជា តែងតែជួបប្រទះនូវបញ្ហាធនធានជារៀងរាល់ឆ្នាំ តាមការអង្កេតមើល រៀលរាល់ឆ្នាំក្នុងឆមាសទីមួយ គ្រប់ក្រសួងស្ថាប័នចំណាយធម្មតា ក្នុងឆមាសទីពីរការចំណាយមានភាពត្បិតត្បៀត។ បញ្ហាកង្វះធនធាននេះត្រូវបានក្លាយជាបញ្ហាដ៏ធ្ងន់នៅពេលវិបិត្តកូវីដ-១៩ផ្ទុះឡើង ហើយរាជរដ្ឋាភិបាលបានសម្រេចកាត់កញ្ចប់ថវិកាហាសិបភាគរយ(៥0%) គ្រប់ក្រសួងស្ថាប័នទាំងអស់ លើកលែងតែបីស្ថាប័នគឺ ក្រសួងការបរទេស ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងការពារជាតិ។ ដូចនេះ ក្រសួងដែលទើបបង្កើតថ្មីដែលទទួលបន្ទុកវិស័យ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ដែលចាំបាច់ត្រូវសាងសង់មជ្ឈមណ្ឌលទិន្នន័យ(Data Center) មន្ទីរពិសោធន៍ និងអគារសម្រាប់អង្គភាពថ្មីដែលទើបតែបង្កើតឡើង ជាហេតុធ្វើឲ្យឯកឧត្តមកត្តិសេដ្ឋាបណ្ឌិតទេសរដ្ឋមន្ត្រី ស្នើសុំទៅរាជរដ្ឋាភិបាលនូវកញ្ចប់ថវិកាពិសេស ដែលជាកញ្ចប់ថវិកាក្នុងករណីពិសេសលើកលែង ក្នុងខណៈដែលរាជរដ្ឋាភិបាលត្រូវត្បិតត្បៀតចំណាយ ប៉ុន្តែសុំលើកលែងមួយចំពោះក្រសួងទើបបង្កើតថ្មី ដែលចាំបាច់ត្រូវការនូវកញ្ចប់ថវិកាពិសេសមួយខុសពីក្រសួងដែលមានស្រាប់ [42] ។ ថ្វីត្បិតតែបញ្ហាធនធានត្រូវបានសង្កត់ធ្ងន់ដោយវិបិត្តសេដ្ឋកិច្ចដែលបណ្តាលមកពីការផ្ទុះរីករាលដាលនៃវីរុសកូវីដ-១៩ក្តី បញ្ហាធនធាននេះនៅតែកើតមានមុនពេលរីករាល់ដាលនៃវីរុសនេះទៅទៀត ពោលគឺបញ្ហានេះអាចត្រូវបានឆ្លុះឆ្លាយតាមផ្លូវដោយប្រការផ្សេងៗ ដោយចេតនា ដោយអចេតនាក្នុងការគ្រប់គ្រង ជាពិសេសគឺអង្គភាពនានារបស់ក្រសួងធ្វើការដាច់ពីគ្នា និងត្រូវចំណាយថវិកាធនធានផ្សេងៗគ្នា។ ប្រសិនបើយើងអាចបញ្ចូលសេវា ឬប្រើប្រាស់បច្ចេកវិទ្យាដើម្បីប្រើប្រាស់សម្ភារៈ ឬឧបករណ៍រួមបាន យើងក៏អាចសន្សំសំចៃធនធានច្រើនដែល។ ឧទាហរណ៍ កុំព្យូទ័រ ព្រីនធ័រ បច្ចុប្បន្នគឺ ចាំបាច់ត្រូវមានក្នុងមួយការិយាល័យមួយ ប៉ុន្តែសម័យបច្ចេកវិទ្យាទំនើបគេអាចប្រើព្រីនធ័រនៅមួយកន្លែងដោយមិនប្រើខ្សែហើយអាចប្រើរួមគ្នាបាន។ កង្វះខាតសម្ភារ ឧបករណ៍ពិសោធន៍សំខាន់ៗដែលមានតម្លៃថ្លៃ សម្រាប់បម្រើការងារមន្ទីរពិសោធន៍ និងឧបករណ៍បច្ចេកទេសដទៃទៀត ដើម្បីបម្រើការងារវិស័យមាត្រាសាស្ត្រ ត្រួតពិនិត្យសុវត្ថិភាព និងបរិស្ថានឧស្សាហកម្ម ជាពិសេសផ្នែកសុវត្ថិភាពម្ហូបអាហារ[43]។ ការកំណត់បេសកកម្មដោយផ្អែកលើផែនការសកម្មភាព ដែលផ្តើមចេញពីគោលនយោបាយរបស់ក្រសួង និងការរៀបចំថវិកាតាមកម្មវិធី របស់ក្រសួងនៅ ពុំទាន់ព្យាករណ៍ឲ្យអស់លទ្ធភាព ជា

[41] របាយការណ៍ បូកសរុបលទ្ធផលការងាររបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប្រចាំឆ្នាំ២០១៩ និងទិសដៅការងារឆ្នាំ២០២០

[42] សារុន បូទ្ធា(រដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍)

[43] របាយការណ៍ បូកសរុបលទ្ធផលការងាររបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប្រចាំឆ្នាំ២០១៩ និងទិសដៅការងារឆ្នាំ២០២០

ពិសេស កត្តាហានិភ័យ សត្យានុម័តដែលលេចពេលអនុវត្តការងារ ដូចជាការគ្រោងថវិកាតាមកម្មវិធីពុំទាន់ឆ្លុះបញ្ចាំងទៅនិងលទ្ធផលរំពឹងទុក ជាហេតុនាំឲ្យជួបបញ្ហាលំបាកក្នុងការប្រើប្រាស់ថវិកា កន្លែងខ្លះមានតម្រូវការថវិកា ហើយបានដោះស្រាយ ប៉ុន្តែពុំទាន់ឆ្លើយតបនឹងតម្រូវការ[44]។ លទ្ធភាពទទួលបានហិរញ្ញវត្ថុ ដើម្បីលើកកម្ពស់សមត្ថភាពវិស័យសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្មនៅតែជាបញ្ហាចោទនៅឡើយ ជាពិសេស ការកំណត់គោលដៅអាទិភាពនៅពុំទាន់ឆ្លើយតបនឹងហិរញ្ញវត្ថុ ឬថវិកាដែលមានស្រាប់។

## ៤.៣ បញ្ហាច្បាប់

ជាក់ស្តែងក្រសួងដែលទទួលបន្ទុកលើវិស័យសហគ្រាសធុនតូច និងមធ្យម(SME) កំពុងតែរៀបចំតាក់តែងច្បាប់នេះឡើង[45]។ នេះឆ្លុះបញ្ចាំងឲ្យឃើញថាយើងធ្វើបណ្តើរខ្វះខាតអ្វីយើងធ្វើបណ្តើរ ខុសពីប្រទេសអភិវឌ្ឍន៍គេរៀបចំរចនាសម្ព័ន្ធ ក្របខណ្ឌច្បាប់ គតិយុត្តឲ្យហើយទើបគេដាក់ចេញទៅ។ កង្វះខាតនៃ ច្បាប់ បទដ្ឋានគតិយុត្តដើម្បីគាំទ្រដល់ការអនុវត្តន៍គោលនយោបាយគឺជាបញ្ហាប្រឈមមួយ ប៉ុន្តែបញ្ហាប្រឈមធំជាងនេះទៅទៀតគឺ នៅក្នុងការអនុវត្ត ដោយជួនកាលមានច្បាប់ហើយប៉ុន្តែយើងអនុវត្តន៍អត់បាន។ កន្លងមកដោយមានអង្គការអន្តរជាតិ អង្គការតំបន់ ដៃគូអន្តរជាតិ ដៃគូតំបន់ជាច្រើនបានជួយតាក់តែងច្បាប់ដល់ក្រសួងស្ថាប័ន ដូចជា World Bank ADB GIZ ជាដើម ធ្វើឲ្យយើងមានច្បាប់ល្អៗច្រើនដែលជាស្តង់ដារអន្តរជាតិ ប៉ុន្តែអ្វីដែលសំខាន់គឺការអនុវត្តនៅដដែល។ នៅក្នុងពិភពលោកយើងនេះ មានប្រទេសពីរប្រភេទដែលទាក់ទងនិងច្បាប់ ទី១ប្រទេសដែលមានច្បាប់ច្រើន ប៉ុន្តែការអនុវត្តច្បាប់គឺគ្មានប្រសិទ្ធិភាព និងប្រទេសដែលមានច្បាប់តិច ប៉ុន្តែការអនុវត្តច្បាប់មានភាពល្អប្រសើរ។ ឯកសារបទដ្ឋានគតិយុត្ត គោលនយោបាយច្បាប់ សម្រាប់គាំទ្រ និងលើកកម្ពស់ការគ្រប់គ្រង និងអភិវឌ្ឍន៍វិស័យនានារបស់ក្រសួងនៅមានចំណុចខ្លះគួរធ្វើវិសោធ ឬកែសម្រួលបំពេញបន្ថែម សំដៅឆ្លើយតបទៅនិងទំហំនៃការរីកចម្រើនបច្ចុប្បន្ន រួមជាមួយកង្វះខាតផែនការយុទ្ធសាស្ត្ររយៈពេលខ្លី មធ្យម និងវែង។

ក្រៅពីបញ្ហាប្រឈមសំខាន់ៗបីខាងលើក៏នៅមានបញ្ហាមួយចំនួនទៀតដូចជាៈ (១)សហគ្រាសធុនតូច និងមធ្យម និងសិប្បកម្មស្ថិតនៅរាយប៉ាយមិនទាន់ប្រមូលផ្តុំនៅឡើយ ហើយយន្តការសម្រាប់ផ្តល់ និងទទួលព័ត៌មានអំពីសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្មនៅមានកម្រិត (២)យន្តការច្រកចេញចូលតែមួយ ឬដំបូលតែមួយសម្រាប់ប្រមូលទិន្នន័យ និងចុះបញ្ជីសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្មមិនទាន់ដំណើរការពេញលេញនៅឡើយ ត្រូវការពេលវេលា និងការចូលរួមរបស់ស្ថាប័នពាក់ព័ន្ធ (៣)គុណភាព និងផលិតភាពអំបិលនៅមានកម្រិត ហើយដីស្រែអំបិលកាន់តែរួមតូចទៅៗ (៤)សហគ្រាស និងអង្គភាពរដ្ឋាទឹកមួយចំនួននៅមិនទាន់មានលទ្ធភាពគ្រប់គ្រាន់ក្នុងការប្រមូល និងបង្កើតហិរញ្ញប្បទានឲ្យបានគ្រប់គ្រាន់តាមតម្រូវការ សម្រាប់ការពង្រឹង និងអភិវឌ្ឍន៍អង្គភាព

---

[44] របាយការណ៍ បូកសរុបលទ្ធផលការងាររបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប្រចាំឆ្នាំ២០១៩ និងទិសដៅការងារឆ្នាំ២០២០

[45] សារុន បុទ្ធា(រដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍)

របស់ខ្លួន (៥)បើទោះមានការអភិវឌ្ឍ និងកែលម្អហេដ្ឋារចនា សម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាត តាមបណ្តារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មួយចំនួនហើយក៏ពិតមែន តែពុំទាន់ធានាបាននូវការផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋឲ្យបានគ្រប់គ្រាន់តាមសេចក្តីតម្រូវការនៅឡើយ នៅតាមតំបន់ទីប្រជុំជនមួយចំនួន ជាពិសេសបញ្ហាលើកកម្ពស់គុណភាពទឹក និងការបាត់បង់ទឹក (៦)ប្រភពទឹកនៅតំបន់មួយចំនួន ទទួលរងនូវការបំពុលដោយសារទឹកសំណល់ពីលំនៅដ្ឋាន វិស័យសេវាកម្ម កសិកម្ម ឧស្សាហកម្ម (៧)កង្វះខាតមជ្ឈមណ្ឌលបណ្តុះបណ្តាល និងស្រាវជ្រាវលើ វិស័យទឹកស្អាត (៨)ការអភិវឌ្ឍវិស័យនានារបស់ក្រសួង បានជួបការលំបាកក្នុងការរៀបចំផែនការសកម្មភាពដែលតម្រូវឲ្យគិតគូរដល់បញ្ហាថវិកា ជាពិសេសត្រូវរង់ចាំដៃគូរអភិវឌ្ឍន៍ ឬជំនួយ។ ក្នុងនោះអង្គភាពរដ្ឋាទឹកសាធារណៈនៅតាមបណ្តាខេត្តមួយចំនួនកំពុងមានតម្រូវការពង្រីកបណ្តាយផ្គត់ផ្គង់ទឹកស្អាត ដែលកន្លងមកបានធ្វើមួយចំនួនតែនៅមានកម្រិត (៩)នៅខ្វះកិច្ចសហការពីក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ក្នុងការចែករំលែកព័ត៌មាន និងទិន្នន័យលើការងារមួយចំនួន ក៏ដូចជាប៉ះប៉ូវសំណងខូចខាតប្រព័ន្ធបណ្តាយទុយោទឹកស្អាត បណ្តោយមកពីសកម្មភាពអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនានា ដូចជាការជីកកប់ដាក់លូ ខ្សែកាប សាងសង់ផ្លូវ ស្ពាន (១០)ការងារមួយចំនួនដែលបានធ្វើប្រតិភូកម្មអំណោយទៅឲ្យថ្នាក់ក្រោមជាតិ នៅមិនទាន់បានបំពេញឲ្យរលូន ដូចជាការត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍មាត្រាសាស្ត្រ ការត្រួតពិនិត្យទំនិញផលិត និងទំនិញវេចខ្ចប់ (១១)ការយល់ដឹងរបស់ពាណិជ្ជកម្ម អាជីវករ សិប្បករ សេវាករ នៅមានកម្រិត ពាក់ព័ន្ធនឹងវិស័យជំនាញរបស់ក្រសួង ដូចជាវិស័យមាត្រាសាស្ត្រ ស្តង់ដារ ការរៀបចំប្រព័ន្ធគ្រប់គ្រងគុណភាពឲ្យស្របតាមស្តង់ដារអន្តរជាតិ[46]។

ពាក់ព័ន្ធនឹងបញ្ហាប្រឈមខាងលើ ក្រសួងបានខិតខំដោះស្រាយ និងកាត់បន្ថយបញ្ហាជា បណ្តើរៗជាពិសេសក្នុងនោះ បញ្ហាកង្វះខាតថវិកា និងមន្ត្រីបម្រើការងារ គឺជាកត្តាសត្យានុម័ត ដែលទាមទារឲ្យគ្រប់អង្គភាពពាក់ព័ន្ធដែលមានបញ្ហានេះ ត្រូវឈរលើស្មារតីខិតខំរៀបចំ និងដោះស្រាយឲ្យមានលក្ខណៈសមស្រប និងមិនសុទិដ្ឋនិយម។

[46] សារុន បូទ្មា (រដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍)

# សេចក្តីសន្និដ្ឋាន

វិស័យឧស្សាហកម្ម និងសិប្បកម្មនៅកម្ពុជាបច្ចុប្បន្ន បានធ្វើឲ្យកំណើនសេដ្ឋកិច្ចកាន់តែរីកចម្រើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ។ លទ្ធផលសំខាន់ៗតាមបណ្តាវិស័យជំនាញដូចបានបញ្ជាក់ខាងលើ សរបង្ហាញឲ្យឃើញថា វិស័យឧស្សាហកម្ម និងសិប្បកម្ម កំពុងមានការអភិវឌ្ឍឈានទៅមុខប្រកបដោយនិរន្តរភាព មានលក្ខណៈចម្រុះសម្បូរបែប មានការទទួលខុសត្រូវខាងបរិស្ថាន និងសង្គមខ្ពស់ ហើយពង្រីកបាននូវអន្តរកម្មសេដ្ឋកិច្ច រវាងផ្នែកកែច្នៃ កម្មន្តសាលជាមួយ វិស័យកសិកម្ម ពាណិជ្ជកម្ម និង សេវាកម្ម ដើម្បីជំរុញសមាហរណកម្មសេដ្ឋកិច្ច ខ្សែសង្វាក់តម្លៃ មានភាពប្រកួតប្រជែងរបស់កម្ពុជានៅក្នុងតំបន់ និងពិភពលោក។ ដើម្បីជំរុញ និងលើកកម្ពស់ការអភិវឌ្ឍវិស័យឧស្សាហកម្ម និងសេវាកម្ម ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បាននិងកំពុងយកចិត្តទុកដាក់អភិវឌ្ឍន៍ឧស្សាហកម្ម ស្របតាមនិន្នាការថ្មីនៃពិភពលោក ក្នុងការត្រៀមរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថលក្នុងបរិបទបដិវត្តឧស្សាហកម្មជំនាន់ទី៤ ឬ ឧស្សាហកម្ម 4.0 ដើម្បីច្បាមចាប់យកឱកាសឱកាស ជំរុញការរីកចម្រើននៃទីផ្សារធុរកិច្ចបច្ចេកវិទ្យា ក៏ដូចជា ជំរុញ និងលើកកម្ពស់ការស្រាវជ្រាវ និងនវានុវត្តន៍ ក៏ដូចជាការគ្រប់គ្រង់ និងកាត់បន្ថយនូវហានិភ័យ ដែលអាចកើតឡើងជាយថាហេតុ ដោយបច្ចេកវិទ្យាទាំងនោះ។ក្រសួងកំពុងយកចិត្តទុកដាក់ ក្នុងការលើកកម្ពស់សហគ្រិនភាព និងការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម ក្នុងការបង្កើតការងារ សមរម្យថ្មី និងតម្រង់ទិសដៅ រួមជាមួយការបង្កើតការងារ និងកែសម្រួលក្របខ័ណ្ឌគតិយុត្ត និងបទប្បញ្ញតិគាំទ្រដែលពាក់ព័ន្ធ។

# អនុសាសន៍

ដើម្បីឆ្លើយតបទៅនិងការប្រើប្រាស់ និងតម្រូវការនៃទីផ្សារក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដែលប្រែឈ្មោះទៅជា ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍គប្បីយកចិត្តទុកដាក់បន្ថែម ទៅលើគុណភាព និងស្តង់ដារនៃរបស់ប្រើប្រាស់។ ដោយនាងខ្ញុំយល់ឃើញថាសព្វថ្ងៃ មានម្ហូបអាហារ ភេសជ្ជៈ និងគ្រឿងទេសជាច្រើនដែលគ្មានគុណភាព និងគ្មានស្តង់ដារក្នុងការប្រើប្រាស់ កំពុងចរាចរលើទីផ្សារយ៉ាងខ្លាំង។ ឧទាហរណ៍ កាលពីថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២០នេះមានការពុលស្រាចិនសែ ដែលធ្វើឲ្យមនុស្សស្លាប់ និងរងគ្រោះជាច្រើននាក់។ អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាប់ការក្លែងបន្លំ បានធ្វើការត្រួតពិនិត្យ និងរកឃើញសារធាតុមេតាណុលមានកម្រិតខ្ពស់ ដែលបណ្តាលឲ្យស្លាប់បានប្រសិនបើអ្នកប្រើប្រាស់ច្រើន។ នេះសរបញ្ជាក់ឲ្យឃើញពីកង្វះខាតខាងការត្រួតពិនិត្យស្តង់ដារ គុណភាពផលិតផល។ ជាពិសេស ក្រសួងគួរចាត់មន្ត្រីដែលពាក់ព័ន្ធឧស្សាហ៍ចុះទៅពិនិត្យទីតាំងផលិត ដើម្បីធានាបានថាផលិតផលទាំងនោះមានស្តង់ដារ និងមានអនាម័យ ដើម្បីឲ្យអ្នកដែលប្រើប្រាស់ផលិតផលទាំងនោះមានទំនុកចិត្តក្នុងការប្រើប្រាស់ និងមិនប៉ះពាល់សុខភាពរបស់ពួកគេ។

# ឯកសារយោង

## ច្បាប់ និង បទបញ្ញត្តិផ្សេងៗ


- រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា, ឆ្នាំ១៩៩៣
- ព្រះរាជក្រមលេខ នស/ រកម/ ១២១៣/ ០១៨, ០៦ ធ្នូ ២០១៣, មាត្រា១។
- ព្រះរាជក្រមលេខ នស/ រកម/ ០៣២០/ ០០៩, ២៦ មីនា ២០២០, មាត្រា១។


## សៀវភៅ និងឯកសារផ្សេងៗ


- របាយការណ៍ បូកសរុបលទ្ធផលការងាររបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប្រចាំឆ្នាំ២០១៩ និងទិសដៅការងារឆ្នាំ២០២០
- គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥
- អង្គការលេខរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ឯកឧត្តម សារុន ឫទ្ធា (រដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍)


## គេហទំព័រ


- សារឌី. (២០១៨). *ព្រះរាជាណាចក្រកម្ពុជាទី២ (១៩៩៣-បច្ចុប្បន្ន)*. ដកស្រង់ចេញពី https://khmerdeng.com/kingdom-of-cambodia-2nd-time/
- www.mme.gov.kh

# ឧបសម្ព័ន្ធ